ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៣០ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីទៀងរាល់សប្ដាហ៍.

ក

មាតិកា

I . ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

២២-៨-១៩៩៥ – ព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ១៤២១

២–ព្រះរាជក្រឹត្យ

២៣-៨-១៩៩៥ – ព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៥/៦១ ១៤៥០

II.ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

១៧-៨-១៩៩៥ – អនុក្រឹត្យលេខ ៦៤ អនក្រ. បក. ស្តីពីបញ្ជាចំណាយឥតគ្រោងទុកដែលមានលក្ខណៈចាំបាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាល ១៤៥១

២១-៨-១៩៩៥ – អនុក្រឹត្យលេខ ៦៥ អនក្រ. បក ស្តីពីការបញ្ជាចំណាយឥតគ្រោងទុកដែលមានលក្ខណៈចាំបាច់ និង បន្ទាន់របស់ក្រសួងការពារជាតិ ១៤៥២

១៦-៨-១៩៩៥ – អនុក្រឹត្យលេខ ៨៧ អនក្រ. ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយទាហាន ១៤៥៤

១៦-៨-១៩៩៥ – អនុក្រឹត្យលេខ ៨៨ អនក្រ.តត ស្តីពីការកែសំរួលឋានន្តរសក្តិ និងតែងតាំងមុខងារនាយទាហាន ១៤៥៥
១៧-៨-១៩៩៥ – អនុក្រឹត្យលេខ ៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៥៦
១៧-៨-១៩៩៥ – អនុក្រឹត្យលេខ ៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៥៧
១៧-៨-១៩៩៥ – អនុក្រឹត្យលេខ ៩១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៤៥៨
១៨-៨-១៩៩៥ – អនុក្រឹត្យលេខ ៩២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៥៩
១៨-៨-១៩៩៥ – អនុក្រឹត្យលេខ ៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៦០

២-សេចក្តីសំរេច

១៧-៨-១៩៩៤ – សេចក្តីសំរេចលេខ ៥៨ សសរ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ ចំនួនទាហាន ១៤៦១

III - ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១៧-៨-១៩៩៥ – ប្រកាសលេខ ១០៤ សហវ.ប្រក.ប ស្តីពីការតែងតាំងមន្ត្រីរាជការ ១៤៦៨
២៣-៨-១៩៩៥ – ប្រកាសលេខ ១១២ ប្រក.សហវ.គរ ស្តីពីការតែងតាំង និងផ្ទេរភារកិច្ចមន្ត្រីគយ និងរដ្ឋាករ ១៤៦៩
១៨-៨-១៩៩៥ – ប្រកាសលេខ ៣០១ ប្រក.សហវ.ថ ស្តីពីការបង្វែរឥណទាន ១៤៧១
២៣-៨-១៩៩៥ – ប្រកាសលេខ ៣០៥ ប្រក.សហវ.ថ ស្តីពីការបង្វែរឥណទាន ១៤៧២

២-ស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

២១-៨-១៩៩៥ – ប្រកាសលេខ ៦៥០ ឧក.ប្រក អនុញ្ញាតអោយលោក ហ៊ិន វ៉ាន

ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៨ សេះ ១៤៧៤

២១-៨-១៩៩៥ – ប្រកាសលេខ ៦៥១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី អ៊ូ សុត្ថា ជនជាតិខ្មែរ បើកដំណើរការឡផលិតនំប៉័ង ១៤៧៤

២១-៨-១៩៩៥ – ប្រកាសលេខ ៦៥៣ ផក.ប្រក អនុញ្ញាតអោយលោក ជុក ប៉ាត ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤សេះ ១៤៧៥

២១-៨-១៩៩៥ – ប្រកាសលេខ ៦៥៤ ផក.ប្រក អនុញ្ញាតអោយលោក កុយ គង់ ជនជាតិខ្មែរ បើកដំណើរការផលិតកម្មទឹកកកដើម ១៤៧៥

២៣-៨-១៩៩៥ – ប្រកាសលេខ ៦៥៨ ផក.ប្រក អនុញ្ញាតអោយលោក ស៊ីវ ខៃ ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០សេះ ១៤៧៦

២៣-៨-១៩៩៥ – ប្រកាសលេខ ៦៥៩ ផក.ប្រក អនុញ្ញាតអោយលោក សេង សុធា ជនជាតិខ្មែរបើកដំណើរការផលិតកម្មរោងម៉ាស៊ីនផលិតទឹកកកដើម ១៤៧៦

២៣-៨-១៩៩៥ – ប្រកាសលេខ ៦៦០ ផក.ប្រក អនុញ្ញាតអោយលោក អ៊ុន ហឿន ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២សេះ ១៤៧៧

២៣-៨-១៩៩៥ – ប្រកាសលេខ ៦៦១ ផក.ប្រក អនុញ្ញាតអោយលោក ឈុំ សុវណ្ណ ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម ១៤៧៧

២៣-៨-១៩៩៥ – ប្រកាសលេខ ៦៦២ ផក.ប្រក អនុញ្ញាតអោយលោក ស៊ុយ ហ៊ាង ជនជាតិ ខ្មែរ បន្តដំណើរការសិប្បកម្មផលិតនំផ្អែម «ហួរ ហេង» ១៤៧៨

២៣-៨-១៩៩៥ – ប្រកាសលេខ ៦៦៣ ផក.ប្រក អនុញ្ញាតអោយលោក គីក នីន ជនជាតិខ្មែរ បើកដំណើរការផលិតកម្ម ផលិតទឹកកកដើម ១៤៧៨

២៣-៨-១៩៩៥ – ប្រកាសលេខ ៦៦៤ ផក.ប្រក អនុញ្ញាតអោយលោក ព្រំ អ៊ឹម ជនជាតិខ្មែរ បើកដំណើរការផលិតកម្ម ផលិតទឹកកកដើម ១៤៧៩

២៣-៨-១៩៩៥ – ប្រកាសលេខ ៦៦៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ខៀវ ហៀង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ ១៤៧៩

២៣-៨-១៩៩៥ - ប្រកាសលេខ ៦៦៦ ផក.ប្រក អនុញ្ញាតអោយលោក ម៉ាន ធីម ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦សេះ ១៤៧៩
២៣-៨-១៩៩៥ - ប្រកាសលេខ ៦៦៧ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី អ៊ុង ឡាង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០សេះ ១៤៨០
២៣-៨-១៩៩៥ - ប្រកាសលេខ ៦៦៨ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន សុរាគារក្បាលពោធិ ដែលមានលោកហុងស្រ៊ុន ជនជាតិខ្មែរ ជាប្រធានបន្តដំណើរការផលិតកម្ម ១៤៨១
២៣-៨-១៩៩៥ - ប្រកាសលេខ ៦៦៩ ផក.ប្រក អនុញ្ញាតអោយលោក ហេង សុខ ជនជាតិខ្មែរ បើកដំណើរការរោងជាងជួសជុល រថយន្ត ១៤៨១
២៣-៨-១៩៩៥ - ប្រកាសលេខ ៦៧០ ផក.ប្រក ព្រំ សាទី ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២០សេះ ១៤៨១
២៣-៨-១៩៩៥ - ប្រកាសលេខ ៦៧២ ផក.ប្រក ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំតំរោងតាំងពិព័រណ៍ WORLDTECH'95 នៅប្រទេសថៃឡង់ដ៍ ១៤៨២

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងក្រសួងពត៌មាន

ប្រកាស

១៨-៨-១៩៩៥ - ប្រកាសលេខ១៨២/៩៥ ពម.ប្រក អនុញ្ញាតអោយបោះពុម្ពផ្សាយទស្សនាវដ្តី «សមាគមទន្តពេទ្យកម្ពុជា» ដែលមានលោកទន្តបណ្ឌិត ហែម ឈិន ជាចាងហ្វាងការផ្សាយ ១៤៨៥
១៨-៨-១៩៩៥ - ប្រកាសលេខ ១៨៣/៩៥ ពម.ប្រក អនុញ្ញាតអោយលោក សាយ យាន ផ្ទេរចាងហ្វាងការផ្សាយកាសែត «ខ្មែរអង្គរ» ជូនលោក កែម ប្រាក់សុវណ្ណពេជ្រមុនីរត្ន វិញ ១៤៨៥
១៨-៨-១៩៩៥ - ប្រកាសលេខ ១៨៤/៩៥ ពម.ប្រក អនុញ្ញាតអោយកាសែត

«សម្លេងនិស្សិត» បោះពុម្ពផ្សាយ ដែលមានអ្នកស្រី **ជួង រាធី**
ចាងហ្វាងការផ្សាយ ១៤៨៦
១៦-៨-១៩៩៥ – ប្រកាសលេខ ១៨៥/៩៥ ពម.ប្រក អនុញ្ញាតអោយ លោក
ជា សុខ ចាងហ្វាងការផ្សាយកាសែត «សម្លេងពលរដ្ឋខ្មែរ»
ចេញផ្សាយជាភាសាចិន ប្រចាំថ្ងៃបន្ថែមទៀត ១៤៨៨
១៧-៨-១៩៩៥ – ប្រកាសលេខ ១៨៧/៩៥ ពម.ប្រក អនុញ្ញាតអោយទស្សនាវដ្ដី
ឈ្មោះ «អប្សារ៉ាម៉ា»ចេញផ្សាយជាភាសាខ្មែរ និង ភាសាបារាំង
ដោយមានលោក **គឹម ទិមល** ជាចាងហ្វាងការផ្សាយ ១៤៨៩
២៣-៨-១៩៩៥ – ប្រកាសលេខ ១៨៨/៩៥ ពម.ប្រក ស្ដីពីការយល់ព្រមទទួល
ស្គាល់មន្ត្រីរាជការ ១៤៩០

៤-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

២១-៨-១៩៩៥ – ប្រកាសលេខ ៥៩៥ សក.ដជ ស្ដីពីការទទួលស្គាល់ភាគហ៊ុន
បន្ទុយ និង បន្ថែមរបស់រដ្ឋ នៅក្នុងក្រុមហ៊ុនកម្ពុជា នាវាដឹក
ជញ្ជូន «កាំត្រង់ស៊ីប» ១៤៩១

៥-ទីស្ដីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

២១-៨-១៩៩៥ – ប្រកាសលេខ ១៥១ ប្រក.វវស.បុ ស្ដីពីការលុបឈ្មោះ
មន្ត្រីរាជការ ១៤៩៤

៦-ទីស្តីការរដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

១៨-៨-១៩៩៥ – ប្រកាសលេខ ១៤៧៩ បស្ថ ស្តីពីដាក់អោយប្រើប្រាស់ឯកសណ្ឋានរបស់មន្ត្រីរាជការ ក្រសួងគ្រប់គ្រងបរិដ្ឋ ១៤៩៥

៧-ទីស្តីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ប្រកាស

១៦-៨-១៩៩៥ – ប្រកាសលេខ ១៧៣១ អជប ស្តីពីការតែងតាំងមន្ត្រីរាជការ ១៤៩៨

៨–ទីស្តីការក្រសួងធម្មការ និងសាសនា

ប្រកាស

១៨-៨-១៩៩៥ – ប្រកាសលេខ ១៧១ /៩៥ កធស.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួង ១៥០១
២៣-៨-១៩៩៥ – ប្រកាសលេខ ១៧២ /៩៥ កធស. សេចក្តីសំរេច ស្តីពីការអនុញ្ញាតឲ្យាប់អោយសាងសង់វិហារឥស្លាម ខេត្តកំពង់ចាម ១៥០២

៩-ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

២៣-៨-១៩៩៥ – ប្រកាសលេខ ១០៥ /៩៥ បទ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥០៤

២៣-៨-១៩៩៥ – ប្រកាសលេខ ១០៤ បទ.ប្រក អនុញ្ញាតអោយលោក ម៉ា ឈឿន ប្រធានក្រុមហ៊ុន បុប្ផាអង្គរទេសចរណ៍ ផ្ទាកឈប់ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF និង VHF ចំនួន ០៤ គ្រឿង ១៥០៥

១០-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងផែនការ

ប្រកាស

២១-៨-១៩៩៥ – ប្រកាសលេខ ០១ ប្រផក ស្ដីពីការចាត់តាំងគណៈកម្មការប្រឡងបញ្ចប់ការសិក្សាជំនាញស្ថិតិសេដ្ឋកិច្ចជំនាន់ VI ១៥០៦

២១-៨-១៩៩៥ – ប្រកាសលេខ ០២ ប្រ.ផ.ក ស្ដីពីការចាត់តាំងអនុគណៈកម្មការ ក្រុមពិនិត្យអនុរក្សក្រុមអនុរក្ស ក្រុមទទួលវិញ្ញាសារ ក្រុមអង្គុលីលេខ និងក្រុមសន្តិសុខ ជំនួយអោយគណៈកម្មការប្រឡងបញ្ចប់ការសិក្សារបស់និស្សិត ជំនាន់ VI ផ្នែកស្ថិតិសេដ្ឋកិច្ច នៅសាលាមធ្យមសិក្សាផែនការ ១៥០៧

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

ព្រះរាជក្រម លេខ នស/រកម/០៨៩៥/០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១និងនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២[illegible] ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរនិងអ[illegible]រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

ប្រកាសឱ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពី លក្ខន្តិកៈមេធាវី ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

លក្ខន្តិកៈមេធាវី

ជំពូកទី ១
បទបញ្ញត្តិទូទៅ

មាត្រា ១.-

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបំរើវិស័យយុត្តិធម៌ ។

វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី ។

មាត្រា ២.-

មេធាវីអាចតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿងរដ្ឋប្បវេណីពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច ។

ក្នុងរឿងព្រហ្មទណ្ឌ មេធាវីជួយការពារជនជាប់ចោទ ហើយមិនអាចតំណាងជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេស នៃច្បាប់ ។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងបទរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីបាន ។

មេធាវីអាចជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ ។

មាត្រា ៣.-

មេធាវីផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត ។

មេធាវីអាចត្រូវបានចាត់តាំងដោយគូក្តី ឬចៅក្រមឲ្យបំពេញមុខងារជាអ្នកផ្សះផ្សាឬជាអ្នកសម្រុះសម្រួល ។ មេធាវីនឹងអាចត្រូវបានចាត់តាំងជាអាជ្ញាកណ្តាលបានលុះត្រាតែមានច្បាប់អនុញ្ញាត ។

មាត្រា ៤.-

ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិ

យុត្តបានឡើយ លើកលែងតែការពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាម នោះជាការងារបន្ទាប់បន្សំនៃមុខរបររបស់ខ្លួន ឬជាមុខងារដែលច្បាប់បាន អនុញ្ញាត ។

មាត្រា ៥.-

មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីប្រទេសក្រៅ ឬដែលប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឲ្យប្រកបវិជ្ជាជីវៈមេធាវី មានសិទ្ធិ ចូលរួមប្រកបវិជ្ជាជីវៈជាមួយមេធាវីខ្មែរ ហើយអមមេធាវីខ្មែរនៅចំពោះមុខ តុលាការ ឬស្ថាប័នដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ។ មេធាវីទាំងនោះ ពុំអាចតំណាងកូនក្តីបានឡើយ ។

មាត្រា ៦.-

មេធាវីបរទេសអាចប្រកបវិជ្ជាជីវៈនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា បានលុះត្រាតែមានការយល់ព្រមពីក្រុមប្រឹក្សាគណៈមេធាវីខ្មែរ ផ្អែកលើ លក្ខណៈសម្បត្តិគ្រប់គ្រាន់របស់មេធាវីនោះ ហើយលុះត្រាតែប្រទេសដើម របស់មេធាវីបរទេសនោះ ផ្តល់លទ្ធភាពដូចគ្នាដល់មេធាវីខ្មែរផងដែរ ។ ការយល់ព្រមអាចត្រូវដកហូតវិញបាន បើមានការប្រព្រឹត្តិខុសក្នុងការ ប្រកបវិជ្ជាជីវៈលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីសម្រេចមិនអនុញ្ញាត ឬដកហូតការអនុញ្ញាតរបស់ក្រុមប្រឹក្សា គណៈមេធាវីមិនឲ្យប្រកបវិជ្ជាជីវៈ ត្រូវជូនដំណឹងក្នុងរយៈពេល ១៥ ថ្ងៃ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងទៅសាមីខ្លួន ។ សេចក្តីសម្រេច នេះអាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល២ខែ ក្រោយពីបានទទួលដំណឹង ។

មាត្រា ៧.-

មេធាវីបរទេសដែលត្រូវបានអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈនេះ ពុំអាចធ្វើ សកម្មភាពទាក់ទាញកូនក្តី ឬផ្សព្វផ្សាយពាណិជ្ជកម្មបានឡើយ ។

ជំពូកទី ២

ការរៀបចំវិជ្ជាជីវៈមេធាវី

ផ្នែកទី ១
គណៈមេធាវី

មាត្រា ៨.-

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការប្រមូលផ្តុំមេធាវីទាំងអស់ ដែលតាំងការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ មេធាវីម្នាក់ៗ ត្រូវជាសមាជិកពេញសិទ្ធិនៃគណៈមេធាវី ក្រោយពីចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី ។

មាត្រា ៩.-

គណៈមេធាវីត្រូវបានដឹកនាំដោយប្រធានមួយរូប និងគ្រប់គ្រងដោយក្រុមប្រឹក្សាគណៈមេធាវី ។ ប្រធានគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ២ ឆ្នាំ ។ អាណត្តិនេះអាចត្រូវបានបន្ត តែមួយអាណត្តិទៀតដោយវិធីបោះឆ្នោត ។

មាត្រា ១០.-

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីមាន :

- ចំនួន ៥ នាក់ ក្នុងករណីគណៈមេធាវី មានសមាជិកមិនលើសពី ៣០ នាក់
- ចំនួន ៩ នាក់ បើមានសមាជិកពី ៣១ នាក់ ទៅ ៥០ នាក់
- ចំនួន ១៣ នាក់បើមានសមាជិកពី ៥១ នាក់ទៅ ២០០ នាក់
- ចំនួន ១៩ នាក់ បើមាន សមាជិកពី ២០១ នាក់ ទៅដល់ ៥០០ នាក់
- ចំនួន ២៧ នាក់ បើមានសមាជិកពី ៥០១ នាក់ទៅ ១.០០០ នាក់
- ចំនួន ៣៣ នាក់ បើមានសមាជិកលើសពី ១០០១ នាក់ ។

មាត្រា ១១.-

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ៣ ឆ្នាំ ។ អាណត្តិនេះអាចបន្តម្តងទៀតបាន ប៉ុន្តែមិនអាចបន្តភ្ជាប់ពីចប់អាណត្តិភ្លាមនោះទេ ។ ផុតរយៈពេល ៣ ឆ្នាំ ក្រោយពីចប់អាណត្តិទើបអតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាថ្មីបាន ។ ប្រធានគណៈមេធាវី អាចត្រូវបានបោះ

ឆ្នោតជ្រើសតាំងឲ្យធ្វើជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីបានក្រោយបានចប់អាណត្តិរបស់ខ្លួន ដោយមិនបាច់រង់ចាំផុតរយៈពេល ៣ ឆ្នាំទេ ។

មាត្រា ១២.-

បើប្រធានគណៈមេធាវី ឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សាគណៈមេធាវីទទួលមរណភាពឬឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួន នោះត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងអ្នកជំនួស ដើម្បីបញ្ចប់អាណត្តិនោះ ។

មាត្រា ១៣.-

គណៈមេធាវីមិនស្ថិតនៅក្រោមគណៈបក្សនយោបាយណាមួយ ឬអង្គការ សាសនាណាមួយ ឬអង្គការនានាផ្សេងទៀតឡើយ ។

ការសម្តែងមនោគមវិជ្ជា សាសនា ឬនយោបាយ ត្រូវហាមឃាត់ ។

គណៈមេធាវីមានថវិកាស្វយ័ត ប៉ុន្តែមិនអាចធ្វើសកម្មភាពយកផលចំណេញបានឡើយ ។

ផ្នែកទី ២

ការបោះឆ្នោត

មាត្រា ១៤.-

ប្រធានគណៈមេធាវី និងសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នា ក្នុងមហាសន្និបាតនៃគណៈមេធាវី ។ អ្នកដែលមានសិទ្ធិបោះឆ្នោត គឺមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីនៃគណៈមេធាវី ហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយឡើយ ។

មាត្រា ១៥.-

អ្នកដែលអាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាប្រធានគណៈមេធាវីបានគឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបានរយៈពេល៣ឆ្នាំយ៉ាងតិច ហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយឡើយ ។

អ្នកដែលអាចឈរឈ្មោះបោះឆ្នោត ជ្រើសតាំងជាសមាជិកក្រុមប្រឹក្សា គណៈមេធាវីបាន គឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបាន រយៈពេល ២ ឆ្នាំយ៉ាងតិចហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតទាំងនោះ ។

មាត្រា ១៦.-

ការបោះឆ្នោតត្រូវបានរៀបចំឡើងដោយមហាសន្និបាតនៃគណៈមេធាវី ២ ឆ្នាំម្តង ចំពោះប្រធានគណៈមេធាវី និង ៣ ឆ្នាំម្តង ចំពោះសមាជិកនៃក្រុមប្រឹក្សា គណៈមេធាវី ។

ការបោះឆ្នោតនេះ ត្រូវប្រព្រឹត្តជាសម្ងាត់ និងជាឯកនាមហើយអាចធ្វើជាពីរលើកបាន ។ ការបោះឆ្នោតលើកទី១ប្រព្រឹត្តទៅដោយយកតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកគណៈមេធាវីទាំងមូល និងលើកទី ២ ដោយយកតាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នាមេធាវី ដែលមានវ័យចាស់ជាងគេ ត្រូវបានជ្រើសតាំង ។

មាត្រា ១៧.-

បែបបទនៃការបោះឆ្នោត ការកោះអញ្ជើញមករួមប្រជុំ និងកូរ៉ុម ត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុង ។ មេធាវីដែលមានសិទ្ធិបោះឆ្នោត ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចប្តឹងតវ៉ាអំពីការបោះឆ្នោតនេះទៅសាលាឧទ្ធរណ៍បាន ។

ពាក្យបណ្តឹងនេះ ត្រូវធ្វើឡើងដោយមេធាវីក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយការបោះឆ្នោត ឬដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទទួលដំណឹងស្តីពីលទ្ធផលនៃការបោះឆ្នោតនោះ ។

ផ្នែកទី ៣

មហាសន្និបាត

មាត្រា ១៨.-

មហាសន្និបាតសាមញ្ញនៃគណៈមេធាវីប្រព្រឹត្តទៅមួយឆ្នាំម្តង ដែលផ្តើម

ធ្វើឡើងដោយប្រធានគណៈមេធាវីតាមរបៀបវារៈ ដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ។

មហាសន្និបាតអាចធ្វើសំណូមពរ ឬញត្តិទៅក្រុមប្រឹក្សាគណៈមេធាវី ដែលត្រូវដោះស្រាយក្នុងរយៈពេល ៣ ខែ ។

មហាសន្និបាតវិសាមញ្ញអាចប្រជុំបាន បើមានមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីចំនួន ៣០% បានស្នើសុំដោយមានភ្ជាប់របៀបវារៈជាមួយផង យ៉ាងតិច ១៥ ថ្ងៃ មុនថ្ងៃប្រជុំ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃមហាសន្និបាតគណៈមេធាវី ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ។

ផ្នែកទី ៤
ក្រុមប្រឹក្សាគណៈមេធាវី

មាត្រា ១៩.-

ក្រុមប្រឹក្សាគណៈមេធាវីពិនិត្យដោះស្រាយគ្រប់បញ្ហា ដែលពាក់ព័ន្ធទៅការអនុវត្តន៍វិជ្ជាជីវៈមេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីធានាការបំពេញភារកិច្ច និងការពារសិទ្ធិរបស់មេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីមានភារកិច្ចជាអាទិ៍ដូចតទៅ ៖

- ធ្វើបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌
- សំរេចឲ្យចុះឈ្មោះធ្វើកម្មសិក្សា និងចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី
- សំរេចលើការស្នើសុំអនុញ្ញាតទាំងឡាយដែលធ្វើឡើងដោយមេធាវី
- ពិនិត្យកិច្ចព្រមព្រៀងនិងឯកសារទាំងឡាយដែលមេធាវីមានកាតព្វកិច្ច ត្រូវដាក់ឲ្យពិនិត្យហើយបញ្ចេញមតិណែនាំលើកិច្ចព្រមព្រៀង និង ឯកសារទាំងនោះ
- ត្រួតពិនិត្យការកាន់កាប់ទៀងទាត់នៃបញ្ជីគណៈនេយ្យរបស់មេធាវី

- ធានាការគោរពវិន័យ និងការដាក់វិន័យ
- ធានារ៉ាប់រងការរៀបចំ និងការគ្រប់គ្រងសេវាទូទៅរបស់គណៈមេធាវី
- គ្រប់គ្រងទ្រព្យសម្បត្តិ និងថវិការបស់គណៈមេធាវីកំណត់ចំនួនទឹកប្រាក់ភាគទានរបស់មេធាវីម្នាក់ៗ និងបង់ប្រាក់ធានារួមសំរាប់វិជ្ជាជីវៈមេធាវី
- គ្រប់គ្រងបេឡានៃមូលនីធិរបស់គណៈមេធាវី
- បញ្ចេញមតិលើបញ្ហាទាំងឡាយដែលទាក់ទងវិស័យយុត្តិធម៌ និងសិទ្ធិរបស់មេធាវី ក្នុងវិស័យការពារជាអាទិ៍នៅពេលដែលមានការអញ្ជើញពីអាជ្ញាធរសាធារណៈ ។

មាត្រា ២០.-

ក្រុមប្រឹក្សាគណៈមេធាវីអាចរួមប្រជុំបាន លុះត្រាតែមានសមាជិករបស់ខ្លួនចូលរួមលើសពីពាក់កណ្ដាល ។ ក្រុមប្រឹក្សាគណៈមេធាវីសំរេចសេចក្ដីតាមមតិភាគច្រើន ។

មាត្រា ២១.-

សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលមានលក្ខណៈជាបទបញ្ជា ត្រូវជូនដំណឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្ដីថាបានទទួល ។ ចំពោះ [illegible] សំរេចដាក់វិន័យក៏ដូចជាសេចក្ដីសំរេចលើការចុះឈ្មោះ ឬការសុំឲ្យនៅក្រៅបញ្ជីរបស់មេធាវី ត្រូវធ្វើដូច្នេះដែរ ។ សេចក្ដីសំរេចចែងក្នុងវាក្យខ័ណ្ឌខាងលើ ត្រូវផ្ដល់ជាពត៌មានដល់សមាជិកនៃគណៈមេធាវីតាមមធ្យោបាយសមស្រប ។

មាត្រា ២២.-

រាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី[illegible]មេធាវីណាម្នាក់ [illegible] ណឹងទៅមេធាវីនោះតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដោយមានចុះសេចក្ដីថាបានទទួល ។

មាត្រា ២៣.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលមិនមែនជាមុខនាទីរបស់ខ្លួនឬផ្ទុយនឹងបទបញ្ញត្តិច្បាប់ជាធរមានឬបទបញ្ជាអាចត្រូវបដិសេធចោលដោយសាលាឧទ្ធរណ៍ក្រោយពីមានការប្តឹងពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មាត្រា ២៤.-

មេធាវីអាចប្តឹងអំពីសេចក្តីសំរេចណាមួយរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលធ្វើឲ្យខាតប្រយោជន៍ដល់វិជ្ជាជីវៈរបស់ខ្លួនបាន ។ បើសេចក្តីសំរេចឥតត្រូវបានឲ្យដំណឹងដល់មេធាវី មេធាវីនោះត្រូវសុំឲ្យក្រុមប្រឹក្សាគណៈមេធាវីពិនិត្យសេចក្តីសំរេចនោះសាជាថ្មីម្តងទៀតមុននឹងប្តឹង ។ ក្រុមប្រឹក្សាគណៈមេធាវី ត្រូវសំរេចលើសេចក្តីស្នើសុំនោះក្នុងរយៈពេល ២ ខែក្រោយពីបានអញ្ជើញមេធាវីនោះឲ្យបញ្ចេញយោបល់របស់ខ្លួន ។ សេចក្តីសំរេចថ្មីត្រូវបានជូនដំណឹងទៅសាមីខ្លួន ។ បើគ្មានការសំរេចសាជាថ្មីក្នុងរយៈពេលដូចកំណត់ខាងលើនេះទេ ត្រូវចាត់ទុកសេចក្តីសំរេចមុននោះជាអសាបង់ ។

មាត្រា ២៥.-

ពាក្យបណ្តឹងទាំងឡាយមិនសុខចិត្តនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ ។ គេអាចដាក់ពាក្យបណ្តឹងទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬតាមលិខិតអនុសិដ្ឋមានចុះសេចក្តីថាបានទទួល ។ រយៈពេលប្តឹងឧទ្ធរណ៍គឺ ២ ខែ ចាប់ពីថ្ងៃទទួលដំណឹង ។

មាត្រា ២៦.-

ក្រុមប្រឹក្សាគណៈមេធាវីត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យនិងផ្សព្វផ្សាយជាសាធារណៈជារៀងរាល់ឆ្នាំ នូវរបាយការណ៍លំអិតស្តីពីសកម្មភាពការងាររបស់គណៈមេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវបង្ហាញស្ថានភាពហិរញ្ញវត្ថុនិងផ្តល់ពត៌មានផ្សេងៗជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បើមានសំណូមពរពីក្រសួងនេះ ។

ផ្នែកទី ៥
ប្រធានគណៈមេធាវី

មាត្រា ២៧.-

ប្រធានគណៈមេធាវីមានតួនាទី ៖

- ជាអ្នកដឹកនាំគណៈមេធាវី
- ជាអធិបតីនៃមហាសន្និបាតគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី
- ជាអ្នកធានាផលប្រយោជន៍វិជ្ជាជីវៈ និងផលប្រយោជន៍របស់សមាជិកទាំងអស់
- ជាអ្នកផ្សះផ្សា ហើយបើមានការចាំបាច់និងតាមសំណើរបស់គូក្តី ធ្វើអាជ្ញាកណ្តាលក្នុងវិវាទដែលកើតឡើងរវាងមេធាវីនិងមេធាវីរវាងមេធាវីនិងអតិថិជន
- ជាតំណាងវិជ្ជាជីវៈមេធាវីចំពោះមុខតតិយជននិងអាជ្ញាធរសាធារណៈ
- ជាតំណាងគណៈមេធាវីក្នុងរឿងក្តីដែលទាក់ទងគណៈមេធាវី ក្រោយពីមានការអនុញ្ញាតពីក្រុមប្រឹក្សាគណៈមេធាវី ។

ក្នុងការបោះឆ្នោតសំឡេងរបស់ប្រធានគណៈមេធាវីឥតមានឧត្តមានុភាពទេ ។

មាត្រា ២៨.-

ប្រធានគណៈមេធាវីអាចផ្ទេរអំណាចណាមួយ ឬអំណាចទាំងអស់ទៅឲ្យសមាជិកណាម្នាក់ ឬច្រើននាក់នៃក្រុមប្រឹក្សាគណៈមេធាវីបាន ក្នុងរយៈពេលមានកំណត់ ។

ក្នុងករណីមានធុរៈ ប្រធានគណៈមេធាវីត្រូវជំនួសដោយសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ដែលមានវ័យចាស់ជាងគេ ។

ផ្នែកទី ៦
មូលនិធិនៃគណៈមេធាវី

មាត្រា ២៩.-

មូលនីធិនៃគណៈមេធាវីបានមកពីការបង់ភាគទាននៃសមាជិកទាំងអស់ និងវិភាគទានផ្សេងៗ ។ នៅក្នុងមូលនីធិនេះត្រូវបង្កើតឲ្យមានបេឡាពិសេសមួយសំរាប់ផ្តល់ប្រាក់កំរៃ ដល់មេធាវីដែលការពារជនក្រីក្រ ។

បេឡាពិសេសនេះអាចទទួលអំណោយ ឬប្រាក់ជំនួយដែលឯកជន អង្គការអន្តរជាតិ ឬរដ្ឋាភិបាលនៃប្រទេសផ្សេងៗ ផ្តល់មកឲ្យដើម្បីការពារជនក្រីក្រ ។

មេធាវីទាំងអស់មានកាតព្វកិច្ចជួយការពារជនក្រីក្រ តាមបែបបទនៃបទបញ្ជាផ្ទៃក្នុង ហើយត្រូវដូចជាជួយការពារអតិថិជនរបស់ខ្លួន ។

មាត្រា ៣០.-

ដែលហៅថាជនក្រីក្រ គឺជនដែលគ្មានទ្រព្យសម្បត្តិ គ្មានប្រាក់ចំណូល ឬដែលមានប្រាក់ចំណូលមិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាព ។

ការកំណត់អំពីភាពក្រីក្រ ត្រូវធ្វើឡើងដោយប្រធានតុលាការ និងក្រឡាបញ្ជីនាយកក្រោយពីបានធ្វើការសើបអង្កេតដល់មូលដ្ឋាន ។

ជំពូកទី ៣

ការទទួលឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី បញ្ជីគណៈមេធាវី

ផ្នែកទី ១

លក្ខខណ្ឌ

មាត្រា ៣១.-

ជនដែលអាចចូលប្រកបវិជ្ជាជីវៈជាមេធាវីបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ ៖

១- ត្រូវមានសញ្ជាតិជាខ្មែរ

២- ត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមាន

តម្លៃសមមូល ។

៣- ត្រូវមានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។ វិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះត្រូវចេញឲ្យដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៤- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬ ផ្តន្ទាទោសជាបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ។ មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

មាត្រា ៣២.-

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាប័ត្រច្បាប់ ៖

- ចៅក្រម ដែលបានបំពេញការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ ឆ្នាំ និងអតីតចៅក្រម ដែលមានសញ្ញាប័ត្រមធ្យមសិក្សាច្បាប់ហើយដែលបានបំពេញក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ ឆ្នាំ ។

មិនចាំបាច់មានវិញ្ញាបនប័ត្រខាងវិជ្ជាជីវៈមេធាវី ៖

- អ្នកមានបរិញ្ញាប័ត្រច្បាប់ ហើយដែលបានបំពេញការងារក្នុងវិស័យច្បាប់ ឬតុលាការលើសពី ២ ឆ្នាំ
- មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ
- អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់ ។

ផ្នែកទី ២

ការទទួលឱ្យប្រកបវិជ្ជាជីវៈមេធាវី

មាត្រា ៣៣.-

ការយល់ព្រមឲ្យប្រកបវិជ្ជាជីវៈមេធាវីត្រូវសំរេចដោយក្រុមប្រឹក្សាគណៈមេធាវី ក្រោយពីបានត្រួតពិនិត្យលើការបំពេញលក្ខខណ្ឌសព្វគ្រប់ដែលមានកំណត់ក្នុងច្បាប់នេះនិងក្រោយពីមានយោបល់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

សេចក្ដីសំរេចត្រូវឲ្យដំណឹងដល់សាមីខ្លួន និងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

ក្រុមប្រឹក្សាគណៈមេធាវីមិនអាចសំរេចមិនយល់ព្រមដោយគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យចូលមកបញ្ចេញយោបល់ជាមុនយ៉ាងតិច១០ថ្ងៃបានឡើយ ។ ការកោះអញ្ជើញនេះ ត្រូវធ្វើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយ មានសេចក្ដីបញ្ជាក់ថាបានទទួល ។

សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី អាចត្រូវបានប្ដឹងតវ៉ាតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ២៥ ខាងលើ ។

មាត្រា ៣៤.-

មេធាវីដែលត្រូវបានទទួលឲ្យប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះមុខសាលាឧទ្ធរណ៍ ដោយមានវត្តមានប្រធានគណៈមេធាវី ហើយបែបដែលមានសេចក្ដីដូចតទៅ ៖

"ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំ ដោយសេចក្ដីថ្លៃថ្នូរដោយសតិសម្បជញ្ញៈ ដោយសេចក្ដីទៀងត្រង់ ដោយមនុស្សធម៌ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

ផ្នែកទី ៣
កម្មសិក្សា

មាត្រា ៣៥.-

មេធាវីដែលទើបបានចុះឈ្មោះ ត្រូវធ្វើកម្មសិក្សារយៈពេល ១ ឆ្នាំ

តាមបែបបទ ដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីលើក លែងតែមេធាវីណាដែលមានការអនុញ្ញាតឲ្យរួចផុតពីកម្មសិក្សា ។

បែបបទនៃកម្មសិក្សាមានជាអាទិ៍ដូចតទៅ ៖

- ត្រូវទទួលការបំពាក់បំប៉នជាបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី
- ត្រូវចូលរួមបំរើការងារឲ្យពិតប្រាកដជាសហការីក្នុងការិយាល័យមេធាវីណាមួយ ។

មាត្រា ៣៦.-

កម្មសិក្សាប្រព្រឹត្តទៅក្រោមការត្រួតពិនិត្យរបស់មេធាវីម្នាក់ដែលក្រុមប្រឹក្សាគណៈមេធាវីចាត់តាំងជាប្រធានទទួលខុសត្រូវលើកម្មសិក្សានោះ ។

មាត្រា ៣៧.-

ក្រោយបញ្ចប់កម្មសិក្សា ក្រុមប្រឹក្សាគណៈមេធាវីសំរេចពីការចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីដោយផ្អែកលើរបាយការណ៍របស់ប្រធានទទួលខុសត្រូវលើកម្មសិក្សា ។ ក្រុមប្រឹក្សាគណៈមេធាវី អាចសំរេចឲ្យធ្វើកម្មសិក្សាបន្តទៀតបានតែមិនឲ្យលើសពី ១ ឆ្នាំឡើយ ចំពោះកម្មសិក្សាការីណាដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាត់ទុកជាការលុបឈ្មោះមេធាវីនោះចោល ។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជី ឬការបន្តកម្មសិក្សា ពុំអាចធ្វើទៅបានឡើយបើគ្មានការកោះអញ្ជើញសាមីខ្លួន ឲ្យមកបញ្ចេញយោបល់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា៣៣ ។ សេចក្តីសំរេចនេះអាចនឹងប្តឹងឧទ្ធរណ៍បានតាមល័ក្ខខ័ណ្ឌ និងនីតិវិធីដែលមានចែងក្នុងមាត្រា ២៤ និង ២៥ ។

មាត្រា ៣៨.-

រៀលរាល់ឆ្នាំ ក្រុមប្រឹក្សាគណៈមេធាវីបញ្ចប់បញ្ជីគណៈមេធាវី និងបញ្ជីមេធាវីកម្មសិក្សា ហើយផ្ញើបញ្ជីនោះជូនអគ្គព្រះរាជអាជ្ញា និងសាលាជម្រះក្តីទាំងអស់ ។

បញ្ជីនោះមានដូចតទៅ ៖

- ឈ្មោះមេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវី និងអាស័យដ្ឋានរបស់មេធាវីនោះ
- ឈ្មោះ និងអាស័យដ្ឋានរបស់មេធាវីកម្មសិក្សា ។

មាត្រា ៣៩.-

លេខរៀងនៃការចុះឈ្មោះរបស់មេធាវី ត្រូវកំណត់តាមកាលបរិច្ឆេទដែលបានធ្វើសច្ចាប្រណិធានហើយត្រូវបានកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវី ដែលបានសំរេចឲ្យចុះឈ្មោះ ។

ផ្នែកទី ៤
ការដាក់នៅក្រៅបញ្ជី

មាត្រា ៤០.-

ដោយមានមូលហេតុសមស្រប មេធាវីអាចសុំនៅក្រៅបញ្ជីនៃគណៈមេធាវីបានសំរាប់រយៈពេលពីរឆ្នាំម្តងៗជាអតិបរមា ។

មាត្រា ៤១.-

ក្រុមប្រឹក្សាគណៈមេធាវីអាចសំរេចដាក់មេធាវីណាម្នាក់នៅក្រៅបញ្ជី បើមេធាវីនោះ ស្ថិតនៅក្នុងស្ថានភាពវិសមិតភាព ឬបើមេធាវីនោះពុំអាចប្រកបវិជ្ជាជីវៈរបស់ខ្លួនបាន ។

ក្នុងករណីមានបណ្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចខាងលើនោះ ត្រូវអនុវត្តនីតិវិធី ដែលមានចែងក្នុងមាត្រា ៣៣ ។

មាត្រា ៤២.-

មេធាវីដែលត្រូវបានដាក់ឲ្យនៅក្រៅបញ្ជី ពុំអាចប្រកបវិជ្ជាជីវៈរបស់ខ្លួនហើយក៏ពុំអាចប្រើប្រាស់ឋានៈជាមេធាវីបានឡើយ និងត្រូវបានរួចពីកាតព្វកិច្ចទាំងឡាយដែលទាក់ទងទៅ នឹងវិជ្ជាជីវៈនេះ ក៏ប៉ុន្តែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី ។

ការដាក់ឲ្យនៅក្រៅបញ្ជីពុំអាចរារាំងការចោទប្រកាន់ខាងវិន័យឡើយ ។

ផ្នែកទី ៥
ងារជាមេធាវីកិត្តិយស

មាត្រា ៤៣.-

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្ដល់ងារជាមេធាវីកិត្តិយសជូនមេធាវីដែលឈប់ប្រកបវិជ្ជាជីវៈមេធាវី ក្រោយពីបានប្រកបវិជ្ជាជីវៈរយៈពេល ១៥ ឆ្នាំយ៉ាងតិច ។

មាត្រា ៤៤.-

មេធាវីកិត្តិយសនៅតែជាសមាជិកនៃគណៈមេធាវីដដែល ហើយអាចចូលរួមក្នុងមហាសន្និបាតមេធាវី មានសិទ្ធិផ្ដល់យោបល់ ព្រមទាំងចូលរួមក្នុងពិធីផ្សេងៗ ។

ដោយឡែក មេធាវីកិត្តិយសអាចផ្ដល់យោបល់ដល់អតិថិជន ហើយអាចត្រូវបានចាត់តាំងជាអ្នកផ្សះផ្សា ជាអ្នកសម្រុះសម្រួល ឬជាអ្នកអាជ្ញាកណ្ដាល ។

មាត្រា ៤៥.-

ក្រុមប្រឹក្សាគណៈមេធាវី អាចដកហូតងារជាមេធាវីកិត្តិយសនេះបាន បើមានហេតុដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬសេចក្ដីថ្លៃថ្នូររបស់មេធាវីនោះ ។ ក្នុងករណីនេះត្រូវអនុវត្តនីតិវិធី ដែលមានចែងក្នុងមាត្រា ៣៣ ។

ជំពូកទី ៤
បែបបទនៃការប្រកបវិជ្ជាជីវៈ
ផ្នែកទី ១
ការប្រកបវិជ្ជាជីវៈមេធាវីជាឯកត្តជន ឬជាសមូហភាព

មាត្រា ៤៦.-

មេធាវីអាចប្រកបវិជ្ជាជីវៈជាឯកត្តជនបាន ឬនៅក្នុងក្របខ័ណ្ឌជាក្រុម ឬក្រុមហ៊ុន មេធាវីណាមួយដែលបង្កើតឡើងត្រឹមត្រូវតាមច្បាប់ ។

ក្រុមហ៊ុននេះត្រូវមានលក្ខណៈជាក្រុមហ៊ុនស៊ីវិល ហើយមានសុទ្ធតែ

មេធាវីជាសមាជិក ។ មេធាវីកិត្តិយសអាចនៅជាសមាជិកនៃក្រុមហ៊ុនដើមរបស់ខ្លួនបាន ។

សិទ្ធិវន្ត គឺអ្នកដែលមានសិទ្ធិទទួលមរតកពីមេធាវី ដែលបានទទួលមរណភាពអាចបន្តកាន់កាប់ភាគហ៊ុននោះបានក្នុងរយៈពេល៣ឆ្នាំជាអតិបរមា ។ ផុតរយៈពេល ៣ ឆ្នាំ នោះត្រូវលក់ភាគហ៊ុននោះទៅឲ្យមេធាវីណាម្នាក់ ឬទៅឲ្យក្រុមហ៊ុននោះវិញ ។

មាត្រា ៤៧.-

ក្រុម និងក្រុមហ៊ុនមេធាវីទាំងឡាយ ត្រូវបានគ្រប់គ្រងដោយច្បាប់គ្រប់គ្រងក្រុមនិងក្រុមហ៊ុន លើកលែងតែបទបញ្ញត្តិនៃបទបញ្ជានោះប៉ះពាល់ដល់គោលការណ៍គ្រប់គ្រងវិជ្ជាជីវៈមេធាវី ។

មាត្រា ៤៨.-

មេធាវីទាំងឡាយត្រូវបានអនុញ្ញាតឲ្យចុះកិច្ចព្រមព្រៀងជាមួយសមាជិកនៃវិជ្ជាជីវៈសេរីដទៃទៀត ដើម្បីប្រមូលផ្តុំមធ្យោបាយជាមួយគ្នា ។ ការធ្វើកិច្ចព្រមព្រៀងនេះមិនត្រូវឲ្យប៉ះពាល់ដល់វិធាននៃវិជ្ជាជីវៈមេធាវី ជាអាទិ៍ប៉ះពាល់ដល់ការគោរពការសម្ងាត់នៃវិជ្ជាជីវៈនេះ ។

មាត្រា ៤៩.-

រាល់កិច្ចព្រមព្រៀងដែលមេធាវីខ្មែរណាម្នាក់បានចុះជាមួយមេធាវីខ្មែរណាម្នាក់ទៀត ឬជាមួយមេធាវីបរទេស ឬក៏ជាមួយសមាជិកនៃវិជ្ជាជីវៈសេរីណាមួយ ត្រូវតែដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងយល់ព្រម ហើយជូនពត៌មានដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ក្នុងករណីនេះត្រូវអនុវត្តនីតិវិធីដែលមានចែងក្នុងមាត្រា ៣៣ ។

ផ្នែកទី ២

កិច្ចសហការ

មាត្រា ៥០.-

មេធាវីអាចប្រកបវិជ្ជាជីវៈក្នុងលក្ខណៈជាសហការីរបស់មេធាវីម្នាក់ទៀត។

មាត្រា ៥១.-

មេធាវីជាសហការីបំពេញកិច្ចការផ្សេងៗក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់សហភាតា ។ គេពុំអាចបំពេញកិច្ចការបានទេ បើគ្មានការយល់ព្រមពីសហភាតា ប៉ុន្តែគេមានសិទ្ធិពេញទីក្នុងការជ្រើសរើសមធ្យោបាយធ្វើការងាររបស់គេ។គេអាចសុំមិនទទួលបំពេញ បេសកកម្មណាមួយដែលគេយល់ថាផ្ទុយ នឹងសម្បជញ្ញៈរបស់គេ ។

មាត្រា ៥២.-

ក្នុងករណីណាក៏ដោយ កិច្ចសហការមិនអាចរារាំងមិនឲ្យសហការីមេធាវីបង្កើតការិយាល័យផ្ទាល់របស់គេ ឬរារាំងមិនឲ្យគោរពតាមតព្វកិច្ចនិងវិធាននៃវិជ្ជាជីវៈមេធាវីបានឡើយ ។ គេធ្វើការក្នុងនាមគេផ្ទាល់ កាលណាគេការពារក្ដីគេផ្ទាល់ខ្លួន ។

កិច្ចសន្យានៃកិច្ចសហការត្រូវរៀបចំឡើង ហើយផ្ញើជូនក្រុមប្រឹក្សាគណៈមេធាវី ។

ជំពូកទី ៥

វិធាននៃវិជ្ជាជីវៈ មនវិន័យ

ផ្នែកទី ១

វិសមិតភាព

មាត្រា ៥៣.-

វិជ្ជាជីវៈមេធាវីមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈ និងការប្រកបមុខរបរពាណិជ្ជកម្ម ទោះការប្រកបនោះដោយប្រយោលក្ដី ឬដោយផ្ទាល់ក្ដី ។

មាត្រា ៥៤.-

មេធាវីដែលបានទទួលតួនាទីក្នុងរាជរដ្ឋាភិបាល ឬទទួលអាណត្តិជាអ្នក

តំណាងរាស្ត្រនៃរដ្ឋសភា អាចនៅជាសមាជិកនៃគណៈមេធាវីបាន ប៉ុន្តែត្រូវឈប់ប្រកបវិជ្ជាជីវៈនេះរហូតដល់ចប់តួនាទី ឬអាណត្តិនោះ ។

មាត្រា ៥៥.-

មេធាវីដែលជាអតីតមន្ត្រីរាជការ អាចធ្វើបទអន្តរាគមន៍ការពារកូនក្តីប្រឆាំង នឹងក្រសួងមន្ទីររដ្ឋបាលដែលខ្លួនស្ថិតនៅក្រោមឱវាទពីមុនបាន លុះត្រាតែផុតរយៈពេល ៥ ឆ្នាំ គិតពីថ្ងៃឈប់ពីមុខងាររបស់ខ្លួន ។

ផ្នែកទី ២

បទវិន័យ

មាត្រា ៥៦.-

វិធាននៃវិជ្ជាជីវៈមេធាវីត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈ-មេធាវី ។ វិធាននេះធានាការគោរពដោយមេធាវីនូវគោលការណ៍ទាំងឡាយនៃសច្ចាប្រណិធានរបស់ខ្លួន ។

មាត្រា ៥៧.-

គ្រប់អំពើទាក់ទាញប្រកាសផ្សាយជាឯកត្តជន ឬទទូចសុំការពាររបស់មេធាវីចំពោះអតិថិជនត្រូវហាមឃាត់ ។

មានតែការប្រកាសផ្សាយវិជ្ជាជីវៈជាសមូហភាពទេ ដែលអនុញ្ញាតឲ្យធ្វើបាន ។ ការប្រកាសផ្សាយនេះ ត្រូវធ្វើឲ្យបានត្រឹមត្រូវ ហើយមិនត្រូវឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មេធាវីឡើយ ។

មាត្រា ៥៨.-

មេធាវីត្រូវតែរក្សាការសម្ងាត់ជាដាច់ខាត ។ មេធាវីកំណត់តាមសតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីអតិថិជនផងនូវអ្វីដែលខ្លួនត្រូវលើកឡើងដើម្បីការពារផលប្រយោជន៍របស់អតិថិជនដែលខ្លួនទទួលបន្ទុក ។

មេធាវីពុំអាចបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាចត្រូវបានបង្ខំឲ្យបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្លួនទោះ

បីនៅមុខតុលាការក៏ដោយ ។

ត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងការផ្តល់យោបល់ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសំរាប់អតិថិជនរបស់ខ្លួនលិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជនរបស់ខ្លួនលិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជន ផ្ញើទាក់ទងគ្នា ។

ផ្នែកទី ៣
ទណ្ឌកម្មជាបទវិន័យ

មាត្រា ៥៩.-

ត្រូវទទួលទណ្ឌកម្មជាបទវិន័យ ចំពោះមេធាវីណាដែលប្រព្រឹត្តល្មើសនឹងវិធាននៃវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។

មាត្រា ៦០.-

ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាគណៈមេធាវីខ្លួនឯងផ្ទាល់ ឬដោយមានពាក្យបណ្តឹងពីតតិយជន ឬដោយមានពាក្យបណ្តឹងពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ក្រុមប្រឹក្សាគណៈមេធាវីចាត់មេធាវីម្នាក់ឲ្យធ្វើជាអ្នករាយការណ៍ ។ ការប្តឹងត្រូវជូនដំណឹងជាមុនទៅសាមីខ្លួនដែលត្រូវដឹងពីសំណុំរឿងនៃការប្តឹងនោះ និងអាចបញ្ចេញយោបល់ការពារខ្លួនបាន ។ បើមានការស៊ើបអង្កេត ក៏ត្រូវផ្តល់ពត៌មាននោះទៅសាមីខ្លួនដែរ ។ របាយការណ៍ ត្រូវផ្ញើជូនសាមីខ្លួនជាមួយនឹងលិខិតកោះអញ្ជើញ ហើយសំណុំរឿងក៏ត្រូវដាក់ឲ្យសាមីខ្លួនពិនិត្យដែរ ។ លិខិតកោះអញ្ជើញត្រូវតែផ្ញើតាមលិខិតអនុសិដ្ឋដោយមានចុះសេចក្តីថាបានទទួល ឬជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១៥ថ្ងៃយ៉ាងតិចមុនថ្ងៃប្រជុំ ។ សាមីខ្លួនអាចជ្រើសរើសយកមេធាវីម្នាក់ឲ្យការពារខ្លួនបាន ។ ប៉ុន្តែសាមីខ្លួនពុំអាចអវត្តមានដោយឲ្យជនណាម្នាក់ធ្វើជាតំណាងជួសខ្លួនបានឡើយ បើគ្មានការអនុគ្រោះយល់ព្រមជាពិសេសជាមុនដោយមានមូលហេតុសម

ស្របទេ ។

បើគ្មានការឆ្លើយតបទៅនឹងបណ្តឹងរបស់អគ្គព្រះរាជអាជ្ញា ឬរបស់គតិយុត្តជនក្នុងរយៈពេល ២ ខែទេ ការមិនឆ្លើយតបពីក្រុមប្រឹក្សាគណៈមេធាវីត្រូវចាត់ទុកជាការបដិសេធបណ្តឹងនោះ ។ ការបដិសេធនេះអាចត្រូវបានប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ ចាប់ពីថ្ងៃផុតរយៈពេល ២ ខែខាងលើ ។

មាត្រា ៦១.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលមានមូលហេតុច្បាស់លាស់ត្រូវបានជូនដំណឹងទៅសាមីខ្លួន និងអគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសំរេចតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃ ដោយមានចុះសេចក្តីថាបានទទួល ។

មាត្រា ៦២.-

ការប្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយសាមីខ្លួន ឬដោយអគ្គព្រះរាជអាជ្ញាទៅសាលាឧទ្ធរណ៍ក្នុងចិរៈវេលា និងតាមទម្រង់ដែលមានចែងក្នុងមាត្រា ២៥ ។ បណ្តឹងឧទ្ធរណ៍ត្រូវជំនុំជំរះជាសម្ងាត់ លើកលែងតែមានសេចក្តីសំរេចផ្ទុយពីនេះរបស់សាលាឧទ្ធរណ៍ តាមការស្នើសុំច្បាស់លាស់ពីមេធាវីដែលត្រូវចោទ ។ គណៈមេធាវីមិនមែនជាភាគីក្នុងរឿងក្តីនេះទេ ប៉ុន្តែប្រធានគណៈមេធាវីត្រូវតែបញ្ចេញយោបល់កត់សំគាល់របស់ខ្លួន ហើយអគ្គព្រះរាជអាជ្ញាត្រូវធ្វើការសន្និដ្ឋាននៅពេលនោះ ។

មាត្រា ៦៣.-

ទណ្ឌកម្មជាបទវិន័យ មានដូចតទៅ ៖

- ការព្រមាន
- ការស្តីបន្ទោស
- ការហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលដែលពុំអាចលើសពី ២ ឆ្នាំ
- ការលុបឈ្មោះចោលពីបញ្ជីនៃគណៈមេធាវី ឬពីបញ្ជីនៃមេធាវីកម្មសិក្សា ឬការ ហូតងារកិត្តិយស ។

មាត្រា ៦៤.-

ទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលអាចព្យួរបាន ។ ប៉ុន្តែបើក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីបានប្រកាសទោសព្យួរនេះ មេធាវីនោះត្រូវបានផ្តន្ទាទោសវិន័យថ្មីមួយទៀត ក្នុងករណីនេះត្រូវអនុវត្តទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈដោយយកទោសថ្មីទៅបូកជាមួយទោសចាស់ដែលបានព្យួរ ។

មាត្រា ៦៥.-

គ្រប់ទណ្ឌកម្ម អាចត្រូវបានបន្ថែមទណ្ឌកម្មហាមឃាត់មិនឲ្យបំពេញជាប្រធានគណៈមេធាវី ឬជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ក្នុងរយៈពេលមិនលើសពី ៥ ឆ្នាំ ។ សេចក្តីសំរេចដាក់ទណ្ឌកម្មនេះត្រូវកំណត់ផងដែរ អំពីការផ្សាយជាសាធារណៈ បើជាការចាំបាច់ត្រូវផ្សាយ ។

មាត្រា ៦៦.-

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្អាកពីមុខងារជាបណ្តោះអាសន្ន ចំពោះមេធាវីណា ដែលបានត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ឬពីបទវិន័យណាមួយដោយបញ្ញត្តិ ឬតាមបណ្តឹងរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ បើគ្មានសេចក្តីសំរេចពីក្រុមប្រឹក្សាគណៈមេធាវីឆ្លើយតបទៅនឹងការការប្តឹងរបស់អគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ២០ ថ្ងៃ នោះនឹងត្រូវចាត់ទុកជាការបដិសេធបណ្តឹងនោះ ។

មាត្រា ៦៧.-

ការផ្អាកពីមុខងារជាបណ្តោះអាសន្នពុំអាចសំរេចបានឡើយ បើគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យចូលមកបញ្ចេញយោបល់របស់ខ្លួន ។ ការកោះអញ្ជើញត្រូវធ្វើឡើងតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួលហើយដែលត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងតិច ៥ ថ្ងៃ មុនថ្ងៃប្រជុំ ។ ការផ្អាកពីមុខងារជាបណ្តោះអាសន្នអាចត្រូវប្តឹងឧទ្ធរណ៍បានក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦២ ។ ការប្តឹងឧទ្ធរណ៍ពុំអាចផ្អាកការអនុវត្តន៍សេចក្តីសំរេចខាងលើបានឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធានា និងឃ្លាំមើលការអនុវត្តន៍ទណ្ឌកម្មខាងវិន័យ និងការផ្អាកពីមុខងារជាបណ្ដោះអាសន្ន ។

ផ្នែកទី ៤

កំរៃ

មាត្រា ៦៨.-

មេធាវីទទួលកំរៃទៅតាមការឯកភាពគ្នាជាមួយអតិថិជន តាមទំហំការងារ តាមទំហំសមត្ថភាពដែលបានបញ្ចេញក្នុងការងារនោះ តាមការលំបាកនៃការងារតាមលទ្ធផលដែលសំរេចបាន ឬតាមតារាងប្រាក់ម៉ោងកំណត់ដោយគណៈមេធាវីរៀងរាល់ឆ្នាំ ។ មេធាវីត្រូវចេញបង្កាន់ដៃ ឲ្យអតិថិជននៅពេលបានប្រាក់កំរៃ ។

មាត្រា ៦៩.-

ការតវ៉ាអំពីកំរៃ ក្រៅពីប្ដឹងទៅតាមនីតិវិធីរដ្ឋប្បវេណី អាចប្ដឹងទៅប្រធានគណៈមេធាវីជាអាជ្ញាកណ្ដាលសំរេចបាន បើមានការយល់ព្រមពីភាគីទំនាស់ ។ សេចក្ដីសំរេចត្រូវឲ្យដំណឹងទៅសាមីខ្លួន តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ ផ្ទាល់ដៃដោយមានចុះសេចក្ដីថាបានទទួល ។ បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើក្នុងរយៈពេល ២ ខែ ក្រោយថ្ងៃទទួលបណ្ដឹង ។ ពាក្យបណ្ដឹងត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬធ្វើតាមលិខិតអនុសិដ្ឋឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្ដីថាបានទទួល ។ បណ្ដឹងឧទ្ធរណ៍នេះត្រូវជំនុំជំរះដោយ ប្រធានសាលាឧទ្ធរណ៍ ឬដោយអ្នកទទួលសិទ្ធិពីប្រធានសាលាឧទ្ធរណ៍ ។

ជំពូកទី ៦

គណនេយ្យ_ការប្រើប្រាស់មូលនិធិ

ការធានា_ប្រាក់ធានារ៉ាប់រង

មាត្រា ៧០.-

មេធាវីដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈមេធាវី មិនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់មូលនីធិរបស់អតិថិជន ឬមូលនីធិទុកសំរាប់អតិថិ

ជនក្នុងពេល ដែលខ្លួនបំពេញបេសកកម្មឲ្យអតិថិជនទេ ។ មូលនីធិនេះបានមកពីប្រាក់ធានាក្តី និងបានមកពីប្រាក់សំណងដែលឈ្នះក្តី ។ មេធាវីត្រូវដាក់មូលនីធិនេះក្នុងគណនីពិសេសមួយដែលបើកឡើងដោយ គណៈមេធាវី ហើយមានឈ្មោះថា «បេឡាទូទាត់របស់គណៈមេធាវី» ។

មេធាវីពុំអាចរក្សាទុកមូលនីធិនេះនៅក្នុងបេឡានោះឲ្យលើសពីថិរៈវេលាចាំបាច់ ដើម្បីសំរេចកិច្ចការដែលអតិថិជនប្រគល់ឲ្យនោះទេ ។ គេពុំអាចកាត់យកកំរៃដែលគេត្រូវទទួល ក្នុងការសំរេចលទ្ធផលការងារពីមូលនីធិខាងលើនេះឡើយ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ។

មេធាវីអាចយកមូលនីធិដែលអតិថិជនបានតម្កល់ទុកសំរាប់បង់ប្រដាប់ក្តី និងកំរៃអ្នកជំនួយការយុត្តិធម៌ទៅបង់ជំនួសអតិថិជនបាន ។

មាត្រា ៧១.-

មេធាវីអាចត្រូវបានតែងតាំងជាអ្នកទទួលទុកបញ្ញើ តាមការព្រមព្រៀងពីភាគី ឬពីចៅក្រម ។ កិច្ចព្រមព្រៀង ឬសេចក្តីសំរេចអំពីការទទួលទុកបញ្ញើត្រូវកំណត់បែបបទ ជាពិសេស បែបបទនៃការប្រាក់ ព្រមទាំងបែបបទបញ្ចប់ទទួលទុកបញ្ញើ ។ មូលនីធិ ឬវត្ថុទាំងឡាយ ត្រូវរក្សាទុកក្នុងបេឡាទូទាត់របស់គណៈមេធាវី ។

មាត្រា ៧២.-

មេធាវីត្រូវមានគណនេយ្យវិជ្ជាជីវៈមួយដោយឡែកស្របតាមច្បាប់ និងបទបញ្ជាផ្ទៃក្នុង ។ ការទូទាត់ប្រើមូលនីធិ ឬវត្ថុបញ្ញើត្រូវធ្វើឡើងក្នុងគណនេយ្យមួយដោយឡែក ។

មេធាវីត្រូវបង្ហាញបញ្ជីគណនេយ្យវិជ្ជាជីវៈរបស់ខ្លួន និងត្រូវបង្ហាញបញ្ជីគណនេយ្យផ្ទាល់ខ្លួនប្រសិនបើមានដល់អ្នកត្រួតពិនិត្យចាត់តាំងឡើងដោយក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា ៧៣.-

មេធាវីត្រូវបង្ហាញថាខ្លួនបានបង់ប្រាក់ធានារ៉ាប់រងតាមរយៈគណៈមេធាវី

សំរាប់ធានារ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនក្នុងវិជ្ជាជីវៈ និងធានារ៉ាប់រងការសងមូលនីធិ និងរបស់មានតម្លៃទាំងឡាយដែលខ្លួនបានទទួលទុក ។ ប្រាក់ធានានោះត្រូវគិតបញ្ចូលក្នុងប្រាក់បង់វិភាគទាន ដែលកំណត់ដោយគណៈមេធាវី ។

ជំពូកទី ៧
ការជំនួស ការខាររដ្ឋបាល

មាត្រា ៧៤.-

មេធាវីដែលអាក់ខានប្រកបវិជ្ជាជីវៈរបស់ខ្លួនជាបណ្ដោះអាសន្ន អាចចាត់តាំងអ្នកជំនួសម្នាក់ដោយមានការយល់ព្រមពីប្រធានគណៈមេធាវី ។ បើគ្មានការចាត់តាំងជំនួសទេនោះ ប្រធានគណៈមេធាវីចាត់តាំងអ្នកជំនួសដោយបញ្ញត្តិ ។

មាត្រា ៧៥.-

សេចក្ដីសំរេចហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈកាល ឬផ្អាកការប្រកបវិជ្ជាជីវៈជាបណ្ដោះអាសន្ន ឬដាក់នៅក្រៅបញ្ជីគណៈមេធាវី ត្រូវចាត់តាំងមេធាវីម្នាក់ឲ្យគ្រប់គ្រងការិយាល័យមេធាវីជំនួស ។ បើអ្នកគ្រប់គ្រងការិយាល័យនោះមានធុរៈ ប្រធានគណៈមេធាវីត្រូវចេញសេចក្ដីសំរេចចាត់តាំងអ្នកជំនួស ។

មាត្រា ៧៦.-

បើមេធាវីម្នាក់ទទួលមរណភាព ឬឈប់ប្រកបវិជ្ជាជីវៈរបស់ខ្លួន ប្រធានគណៈមេធាវីចាត់តាំងមេធាវីម្នាក់ឲ្យទទួលបន្ទុកចាត់ការលើសំណុំរឿងដែលនៅសល់ និងជម្រះបញ្ជីគណនេយ្យ រួចបិទការិយាល័យ ។

ជំពូកទី ៨

ទោសប្បញ្ញត្តិ

មាត្រា ៧៧.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១ ២ ៣ ៤ ៥ ៦ ៧ ១៣ និង ៥៧ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀលទៅដល់ ៥.០០០.០០០ រៀល ។ បើបទល្មើសនោះ ប្រព្រឹត្តឡើងដោយជនបរទេស ជននោះអាចត្រូវបណ្តេញចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាថែមទៀត ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យទ្វេមួយជាពីរ និងអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ ដល់ ៦ ខែ ។

បើមានបទល្មើសខាងលើនេះ ក្រុមប្រឹក្សាគណៈមេធាវីអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ។

មាត្រា ៧៨.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៥៨ ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ ។

ជំពូកទី ៩

អន្តរប្បញ្ញត្តិ

មាត្រា ៧៩.-

តួនាទីការពារកូនក្តីរបស់មេធាវីក្នុងរឿងព្រហ្មទណ្ឌអាចត្រូវបំពេញបានដោយអ្នកការពារក្តី ដែលមិនមែនជាមេធាវី តាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

មាត្រា ៨០.-

អាចត្រូវបានជ្រើសរើសឲ្យប្រឡងចូលរៀនក្នុងវគ្គបណ្តុះបណ្តាលមេធាវី ៖

- អ្នកការពារកូនក្តីដែលមានលទ្ធភាពបំពេញមុខងារនេះ ហើយដែលបំពេញមុខងារនេះពិតប្រាកដ និងជាប់រហូត ២ ឆ្នាំមក នៅតាមតុលាការខេត្តក្រុង។

អ្នកការពារក្ដីទាំងនេះ ត្រូវមានកម្រិតចេះដឹងឧត្ដមសិក្សាពី ២ ឆ្នាំឡើងទៅ ។

- មន្ត្រីរាជការដែលបានបម្រើការងាររដ្ឋ ២ ឆ្នាំ យ៉ាងតិច ហើយដែលមានសញ្ញាប័ត្រមធ្យមសិក្សានីតិសាស្ត្រ ។

អ្នកដែលមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល មិនចាំបាច់ប្រឡងទេ ។

មាត្រា ៨១.-

អាចទទួលឲ្យចុះឈ្មោះ ក្នុងបញ្ជីសំរាប់ឲ្យប្រឡងចូលរៀនក្នុងវគ្គបណ្តុះបណ្តាលមេធាវីបាន ស្របតាមមាត្រាខាងលើ អ្នកដែលមិនដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារពីបទល្មើសព្រហ្មទណ្ឌណាមួយ ។

មាត្រា ៨២.-

វគ្គបណ្ដុះបណ្ដាលមានរយៈពេលយ៉ាងតិច ៨ ខែ ។ កម្មវិធី និងបែបបទនៃវគ្គបណ្ដុះបណ្ដាលព្រមទាំងកម្មវិធី និងបែបបទនៃការប្រឡង ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបណ្ដុះ បណ្ដាលត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីដែលមិនទាន់មានក្រុមប្រឹក្សាគណៈមេធាវី ។

អ្នកដែលប្រឡងជាប់ នឹងត្រូវទទួលវិញ្ញាបនប័ត្រសម្បទា សំរាប់ប្រកបវិជ្ជាជីវៈមេធាវី ។

មាត្រា ៨៣.-

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់ធ្វើកម្មសិក្សាចំពោះ ៖

- អ្នកមានបរិញ្ញាប័ត្រច្បាប់ ឬអ្នកមានសញ្ញាប័ត្រច្បាប់ ដែលបានប្រកាសថា មានតម្លៃសមមូល ហើយបានបំពេីការងារក្នុងវិស័យច្បាប់ ឬតុលាការរយៈពេល ២ ឆ្នា យ៉ាងតិច
- អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់
- ចៅក្រម ឬអតីតចៅក្រមដែលបានបំពេី ារក្នុងវិជ្ជាជីវៈរយៈពេល

យ៉ាងតិច ២ ឆ្នាំ ។

មាត្រា ៨៤.-

មុនពេលបង្កើតបានគណៈមេធាវី អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានភារកិច្ចទទួលនិងពិនិត្យពាក្យសុំប្រកបវិជ្ជាជីវៈមេធាវី ហើយកោះអញ្ជើញអ្នក ដែលបានបំពេញលក្ខខ័ណ្ឌសព្វគ្រប់ ឲ្យមកធ្វើសច្ចាប្រណិធានចំពោះមុខសាលាឧទ្ធរណ៍ដើម្បីបំពេញឋានៈជាមេធាវី និងចូលរួមមហាសន្និបាតបង្កើតគណៈមេធាវី ។

មាត្រា ៨៥.-

មហាសន្និបាតត្រូវរៀបចំបោះឆ្នោត ក្រោមការទទួលខុសត្រូវរបស់មេធាវី ដែលមានវ័យចាស់ជាងគេ ដើម្បីជ្រើសរើសប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី ។

មាត្រា ៨៦.-

មួយឆ្នាំក្រោយមកទៀត ត្រូវរៀបចំការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មីម្នាក់ និងក្រុមប្រឹក្សាគណៈមេធាវីថ្មីមួយ ដោយមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី ។

មាត្រា ៨៧.-

ក្នុងករណីចាំបាច់ អាណត្តិនៃក្រុមប្រឹក្សាគណៈមេធាវី និងប្រធានគណៈមេធាវីដែលជាប់ឆ្នោតលើកដំបូង ត្រូវបន្តរហូតដល់ការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មី និងក្រុមប្រឹក្សាគណៈមេធាវីថ្មី ។

មាត្រា ៨៨.-

ដោយមិនទាន់គិតដល់មាត្រា ១៤ និងមាត្រា ១៥ អ្នកដែលមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតដូចមានចែងក្នុងមាត្រា ៨៤ គឺមេធាវីទាំងឡាយដែលបានចុះឈ្មោះក្នុងបញ្ជីនៃគណៈមេធាវី និងក្នុងបញ្ជីកម្មសិក្សាដោយមិនគិតពីអតីតភាព ។

មាត្រា ៨៩.-

អន្តរប្បញ្ញត្តិនេះ មានអានុភាពអនុវត្តរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ។

ជំពូកទី ១០

អវសានប្បញ្ញត្តិ

មាត្រា ៩០.-

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

ចែម ស្ងួន

នាយករដ្ឋមន្ត្រីទី១

ព្រះហស្តលេខា

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

ហ៊ុន សែន

១-ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ លេខ នស/រកត/០៨៩៥/៦១

យើងព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធវង្ស អគ្គមហាបុរសរតនៈ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង ឯកឧត្តម **នុត សុខុម** ជាអនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាលជំនួសតួនាទីបច្ចុប្បន្នរបស់ឯកឧត្តម **អ៊ុក អាំងគីម** ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* *

II-ទីស្តីការគណៈរដ្ឋមន្ត្រី

១- អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៦៤ អនក្រ.បក

ស្តីពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណៈ

ចាំបាច់ និង បន្ទាន់របស់រាជរដ្ឋាភិបាល

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១ : កំណត់អោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោះស្រាយថវិកា សំរាប់ការចំណាយ ដែលចាត់ទុកជា តម្រូវការប្រញាប់របស់រាជរដ្ឋាភិបាល ដូចខាងក្រោម ÷

ការចំណាយសំរាប់សាងសង់ បន្ទាយសុវត្ថិភាពអោយកំលាំង ការពារនាយករដ្ឋមន្ត្រីទី២ ចំនួន ២២២.៨០០ ដុល្លារអាមេរិក ស្មើនឹង ៥៥៧.០០០.០០០៛ (ប្រាំរយហាសិបប្រាំពីរលានរៀលគត់ គិតតាមអត្រា ២.៥០០៛ ក្នុងមួយដុល្លារអាមេរិក) ។

មាត្រា ២ : សហរដ្ឋមន្ត្រីមទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអាជ្ញាធរពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយបានសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថ លេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៦៥ អនក្រ.បក

ស្តីពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណ:

ចាំបាច់ជាបន្ទាន់របស់ក្រសួងការពារជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងព្រះរាជក្រឹត្យ គស/រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៥ និង

អនុក្រឹត្យ លេខ ៥០ អនក្រ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការបញ្ជាចំណាយឥតគ្រោងទុកដែលមានលក្ខណៈចាំបាច់ និងបន្ទាន់របស់ក្រសួងការពារជាតិ

- យោងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងការពារជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : កំណត់អោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោះស្រាយបន្ថែមថវិកា សំរាប់ការចំណាយក្រៅគំរោងផែនការ ដែលចាត់ទុកជាការប្រញាប់របស់ក្រសួងការពារជាតិ ដែលមានជាលំដាប់លំដោយដូចខាងក្រោម ÷

១–ការចំណាយមានចំនួនទឹកប្រាក់ : ៦៧.៧៨៥ ដុល្លារអាមេរិក (ហុកសិបប្រាំពីរពាន់ប្រាំពីររយប៉ែតសិបប្រាំដុល្លារអាមេរិក) សំរាប់ទិញសម្ភារៈ ប្រើប្រាស់ នៅអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ។

២–ការចំណាយមានចំនួនទឹកប្រាក់ : ២.៧១០.០០០ ដុល្លារអាមេរិក (ពីរលានប្រាំពីររយសិបពាន់ដុល្លារអាមេរិក) សំរាប់ទិញគ្រឿងបំពាក់ និងសម្ភារៈសឹក ដើម្បីបំពេញសេចក្តីត្រូវការសកម្មភាពរដូវប្រាំង ឆ្នាំ ១៩៩៥ របស់កងយោធពលខេមរភូមិន្ទ ។

៣–ការចំណាយមានចំនួនទឹកប្រាក់ ១.៥០០.០០០.០០០៖០០ (មួយពាន់ប្រាំរយលានរៀល) សំរាប់ឧបត្ថម្ភជនភ្ញាក់រលឹក និងគ្រួសារដែលបានចូលមករស់ក្នុងសង្គមជាតិវិញ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយបានសំរេចចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៤៧ អនក្រ.

ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយទាហាន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមុខងារ ផ្ទេរភារកិច្ចចំពោះនាយទាហាន :

១-លោកវរសេនីយឯក **ម៉ាត់ ដារុង្សា** នាយសេនាធិការកងពលធំលេខ ៥ នៃកងយោធពលខេមរភូមិន្ទ បច្ចុប្បន្នស្នើជា នាយរងការិយាល័យទី ៣ អគ្គសេនាធិការ ។

២-លោកវរសេនីយឯក **មុំ មុីន** មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកំពង់ធំ បច្ចុប្បន្នស្នើជា នាយសេនាធិការរងយោធភូមិភាគទី ៤ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង អស់លោកមានឈ្មោះខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយ

ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៤៨ អនក្រ.តត

ស្តីពីការកែសម្រួលឋានន្តរសក្តិ និង តែងតាំងមុខ

ងារនាយទាហាន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមុខងារ និង កែសម្រួលឋានន្តរសក្តិថ្នាក់វរសេនីយ៍ឯកក្នុងកងយោធពលខេមរភូមិន្ទដែលមានរាយនាមដូចខាងក្រោម ÷

១-លោក **ឯម ស៊ាង** មេបញ្ជាការកងរាជអាវុធហត្ថជាតិ ប្រចាំខេត្តព្រៃវែង បច្ចុប្បន្នជានាយសេនាធិការកងពលធំលេខ ៥

២-លោក **ហង្ស ជុំឈ** មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងកំពង់ធំ បច្ចុប្បន្នជា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង កំពង់ធំ

៣-លោក **ខាំ គីមរាន** លេខាធិការរដ្ឋមន្ត្រី ក្រសួងការពារជាតិ បច្ចុប្បន្ន នាយរងខុទ្ទកាល័យអគ្គមេបញ្ជាការ

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីស្រួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ និងសាមីខ្លួនត្រូវអនុវត្តន៍អនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខានិងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៨៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់ រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះលោកឧកញ៉ា **សំ អាង** និងលោកស្រី **ឈុន សាង** ប្រធានក្រុមហ៊ុនវឡៈ ដែលបានឧបត្ថម្ភប្រាក់ ចំនួន ២៧.០០០ ដុល្លារអាមេរិក កសាងសាលារៀននៅភូមិស្វាយតានី ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្ដាល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខានិងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤

អនុក្រឹត្យ លេខ ៩០ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិនិងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះអង្គការជប៉ុន HAND OF PEACE ដែលបានឧបត្ថម្ភប្រាក់ ២៣.១៥៦ ដុល្លារអាមេរិក សំរាប់កសាងវិស័យអប់រំ និងជួយសំរួលជីវភាពអ្នកក្រុមម៉ាយក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៩១ អនក្រ.តត

ស្តីពីការជូនមេដាយសហមេត្រី

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយសហមេត្រីថ្នាក់លេខ ១ ចំពោះឯកឧត្តមឧត្តមសេនីយ៍ **ហ៊ឺសាលតាន់យុទ** អគ្គមេបញ្ជាការកងទ័ពនៃប្រទេសឥណ្ឌូណេស៊ី ដែលមានស្នាដៃដ៏ធំធេងក្នុងការបណ្តុះបណ្តាល ជំនាញកងកុម្ម៉ង់ដូឆ័ត្រយោង និង ជំនាញចិត្តសាស្ត្រដល់កងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៩២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ បាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ

– តាមសំណើរបស់អភិបាលខេត្តរតនគីរី

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថានាជាតិថ្នាក់លេខ ១ ចំពោះសមាគមទ្រទ្រង់សាលារៀន ខេត្តរតនគីរី ដែលបានខិតខំកម្លាំងកាយចិត្តរកប្រាក់បានចំនួន ១៤.០៥៦ ដុល្លារ អាមេរិក កសាងសាលារៀន ០៧ ខ្នង មានបីបន្ទប់ និង សង្ហារឹមសិក្សាសំរេចជាស្ថាពរ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត រតនគីរី ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ; ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៩៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហា ក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ បាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល កម្ពុជា ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះក្រុមហ៊ុន ARISTON ដែល បង្វែរសាច់ប្រាក់ចំនួន ៥០.០០០ ដុល្លារអាមេរិក ចូលថវិការដ្ឋនៅធនាគារជាតិនៃកម្ពុជា ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថ លេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២- សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៥៨ សសរ

ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យចំនួននាយទាហាន

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម** សីហនុ **វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ

- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការចាត់តាំងបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការ
- យោងតាមផែនការកសាងកំលាំងឆ្នាំ ១៩៩៥ ដល់ឆ្នាំ ១៩៩៧ លេខ ២២.៩៤ ផក
- យោងតាមសភាពការណ៍ ជាក់ស្តែងរបស់កងយោធពលខេមរភូមិន្ទ នាពេលបច្ចុប្បន្ន ដើម្បីបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងចំនួនទាហាន ក្នុងកងយោធពលខេមរភូមិន្ទ

សំរេច

ប្រការ ១ : ចាត់តាំងបង្កើតគណៈកម្មការត្រួតពិនិត្យចំនួនទាហាន របស់កងយោធពលខេមរភូមិន្ទ ដើម្បីធ្វើការត្រួតពិនិត្យចំនួនទាហាននិងកូនគ្រប់កងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ និងរៀបចំ ជា ៧ អនុគណៈកម្មការទៀត ដែលស្ថិតនៅក្រោមការដឹកនាំណែនាំផ្ទាល់របស់គណៈកម្មការ ។

ប្រការ ២ : សមាសភាពរបស់គណៈកម្មការ និង អនុគណៈកម្មការ រួមមាន :

ក–គណៈកម្មការត្រួតពិនិត្យចំនួនទាហាន របស់កងយោធពលខេមរភូមិន្ទ មានសមាស ភាពដូចខាងក្រោម :

១–ឯកឧត្តមឧត្តមសេនិយឯក **ទៀ បាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន
២–ឯកឧត្តមឧត្តមសេនិយឯក **ឌា ចាន់ជំរ៉ាត់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន
៣–ឯកឧត្តមឧត្តមសេនិយឯក **កែ គឹមយ៉ាន** នាយអគ្គសេនាធិការ ជាអនុប្រធាន
៤–ឯកឧត្តមឧត្តមសេនិយឯក **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារ ជាតិជាអនុប្រធាន
៥–ឯកឧត្តមឧត្តមសេនិយឯក **ជៀង ដែល** នាយអធិការកិច្ចអគ្គមេបញ្ជាការ ជាអនុប្រធាន
៦–ឯកឧត្តមឧត្តមសេនិយឯក **ញឹក ប៊ុនឆៃ** នាយរងអគ្គសេនាធិការ ជាអនុប្រធាន
៧–ឯកឧត្តមឧត្តមសេនិយឯក **មាស សុភា** នាយរងអគ្គសេនាធិការ ជាអនុប្រធាន
៨–លោក ឧត្តមសេនិយទោ **លី ដេត** នាយកទីចាត់ការបុគ្គលិក ជាសមាជិកអចិន្ត្រៃយ៍
៩–លោក ឧត្តមសេនិយត្រី **ហម គិន** នាយក នាយកដ្ឋានបុគ្គលិក ជាសមាជិកអចិន្ត្រៃយ៍
១០–លោកឧត្តមសេនិយត្រី **ជាំ ឧត្តី** នាយការិយាល័យទី១អគ្គសេនាធិការជាសមាជិកអចិន្ត្រៃយ៍
១១–លោកឧត្តមសេនិយទោ **ម៉ែន ប៊ុនថន** នាយកទីចាត់ការចលនូប្បត្ថម្ភ ជាសមាជិក
១២–លោកឧត្តមសេនិយត្រី **ម៉ម សុជាតិ** នាយករងខុទ្ទកាល័យអគ្គមេបញ្ជាការ ជាសមាជិក

១៣–លោកឧត្តមសេនីយត្រី អ៊ុំ ប្រាត្ន នាយករងអធិការកិច្ចអគ្គមេបញ្ជាការ ជាសមាជិក
១៤–លោកឧត្តមសេនីយត្រី លី យីម៉ុន នាយក នាយកដ្ឋានអធិការកិច្ច ជាសមាជិក
១៥–លោកឧត្តមសេនីយត្រី ទែសេន ចំរុង នាយអធិការកិច្ចអគ្គសេនាធិការ ជាសមាជិក
១៦–លោកឧត្តមសេនីយត្រី ស៊ុំ សំណាង នាយក នាយកដ្ឋានផ្គត់ផ្គង់ ជាសមាជិក
១៧–លោកឧត្តមសេនីយត្រី ម៉ក់ សារុន នាយការិយាល័យទី៤ អគ្គសេនាធិការ ជាសមាជិក
១៨–លោកឧត្តមសេនីយត្រី ម៉ុង សំផន នាយក នាយកដ្ឋានថវិកា ជាសមាជិក
១៩–លោកវរសេនីយឯក អ៊ុំ សារុំ នាយក្រុមហិរញ្ញវត្ថុអគ្គសេនាធិការ ជាសមាជិក
២០–លោកវរសេនីយឯក គួង ម៉ុនឡឿន នាយករងអធិការកិច្ចអគ្គមេបញ្ជាការ ជាសមាជិក
២១–លោកវរសេនីយឯក ម៉ុំ សារី នាយករង នាយកដ្ឋានអធិការកិច្ច ជាសមាជិក
២២–លោកវរសេនីយឯក ម៉ុំ សោភ័ណ្ឌ នាយរងអធិការកិច្ចអគ្គសេនាធិការ ជាសមាជិក

ខ–អនុគណៈកម្មការទាំង ៧ មានសមាសភាពដូចខាងក្រោម ÷

I–អនុគណៈកម្មការទី១

ទទួលបន្ទុកត្រួតពិនិត្យចំនួនទាហានយោធភូមិភាគទី១ រួមមាន ÷

១–ឯកឧត្តម ឧត្តមសេនីយឯក ចាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ ជាប្រធាន
២–លោក ឧត្តមសេនីយទោ ស៊ើយ កែង មេបញ្ជាការយោធភូមិភាគទី១ ជាអនុប្រធាន
៣–លោក ឧត្តមសេនីយត្រី សែន ចំរុង នាយអធិការកិច្ចអគ្គសេនាធិការ ជាអនុប្រធាន
៤–លោក ឧត្តមសេនីយត្រី ស៊ុំ សំណាង នាយក នាយកដ្ឋានផ្គត់ផ្គង់ ជាអនុប្រធាន
៥–លោកវរសេនីយឯក អ៊ុក ដារ៉ិដ ទីចាត់ការបុគ្គលិកអគ្គមេបញ្ជាការ ជាសមាជិកអចិន្ត្រៃយ៍
៦–លោកវរសេនីយទោ សៅ ចាន់ អធិការកិច្ច សេនាធិការ ជាសមាជិក
៧–លោក វរសេនីយទោ ចាន់ សារ៉ម៉ន នាយកដ្ឋានបុគ្គលិក ជាសមាជិក
៨–លោក វរសេនីយត្រី យស់ ឃុន ទីចាត់ការបុគ្គលិក អគ្គមេបញ្ជាការ ជាសមាជិក
៩–លោក វរសេនីយត្រី សោម យុផារីការិយាល័យទី១ អគ្គសេនាធិការ ជាសមាជិក

១០–លោក អនុសេនីយឯក ចាន់ សុវណ្ណ នាយកដ្ឋានអធិការកិច្ច ជាសមាជិក

១១–លោក អនុសេនីយឯក មៅ សុវត្ថា អធិការកិច្ច អគ្គមេបញ្ជាការ ជាសមាជិក

II–<u>អនុគណៈកម្មការទី ២ ទទួលបន្ទុកត្រួតពិនិត្យចំនួនទាហាន</u>

<u>យោធភូមិភាគទី ២ រួមមាន</u> ÷

១–លោក ឧត្តមសេនីយទោ ម៉ែន ម៉ុនថន នាយកទីចាត់ការថលនូបត្ថម្ភ ជាប្រធាន

២–លោក ឧត្តមសេនីយទោ ជៀន សុវណ្ណថា មេបញ្ជាការយោធភូមិភាគទី ២ ជាអនុប្រធាន

៣–លោក ឧត្តមសេនីយត្រី អ៊ុំ ម៉ូរ្យ នាយករងអធិការកិច្ចអគ្គបញ្ជាការ ជាអនុប្រធាន

៤–លោក វរសេនីយឯក ខាត់ ឃីន នាយករងនាយកដ្ឋានបុគ្គលិក ជាសមាជិកអចិន្ត្រៃយ៍

៥–លោក វរសេនីយទោ អន ឆាន ទីចាត់ការបុគ្គលិក អគ្គមេបញ្ជាការ ជាសមាជិក

៦–លោក វរសេនីយទោ គួច សារឿន នាយកដ្ឋានបុគ្គលិក ជាសមាជិក

៧–លោក វរសេនីយទោ ផង់ សារ៉ាវណ្ណ អធិការកិច្ច អគ្គសេនាធិការ ជាសមាជិក

៨–លោក វរសេនីយត្រី ម៉ុង សារឿន នាយកដ្ឋានអធិការកិច្ច ជាសមាជិក

៩–លោក វរសេនីយត្រី អ៊ឹម អាន អធិការកិច្ច អគ្គមេបញ្ជាការ ជាសមាជិក

១០–លោក អនុសេនីយឯក ឈឹម ឈីន ការិយាល័យទី ១ អគ្គសេនាធិការ ជាសមាជិក

III–អនុគណៈកម្មការទី ៣ ទទួលបន្ទុកត្រួតពិនិត្យចំនួនទាហាន

យោធភូមិភាគទី ៣ រួមមាន ÷

១–ឯកឧត្តម ឧត្តមសេនីយឯក ជៀន វែល នាយកទីចាត់ការអធិការកិច្ច អគ្គមេបញ្ជាការ ជាប្រធាន

២–លោក ឧត្តមសេនីយទោ សារិត ឌី មេបញ្ជាការយោធភូមិភាគទី៣ ជាអនុប្រធាន

៣–លោក វរសេនីយឯក ម៉ុំ សាវី នាយករងនាយកដ្ឋានអធិការកិច្ច ជាអនុប្រធាន

៤–លោក វរសេនីយឯក គួន ម៉ុនធឿន នាយរងអធិការកិច្ច អគ្គមេបញ្ជាការ ជាអនុប្រធាន

៥–លោក វរសេនីយឯក ម៉ួន សុមង្គល នាយរងការិយាល័យទី ១ អគ្គសេនាធិការ ជាសមាជិកអចិន្ត្រៃយ៍

៦–លោក វរសេនិយឯក ឡៅ ឃីលី នាយករងទីចាត់ការបុគ្គលិក អគ្គមេបញ្ជាការ ជាសមាជិក

៧–លោក វរសេនិយទោ ទី ធឿន នាយកដ្ឋានបុគ្គលិក ជាសមាជិក

៨–លោក វរសេនិយទោ គឹម ប៊ុនរ៉ាល់ អធិការកិច្ច អគ្គសេនាធិការ ជាសមាជិក

៩–លោក វរសេនិយត្រី ចាន់ សារឿន នាយកដ្ឋានអធិការកិច្ច ជាសមាជិក

១០–លោក វរសេនិយត្រី សៅ សុផា អធិការកិច្ច អគ្គមេបញ្ជាការ ជាសមាជិក

១១–លោក អនុសេនិយឯក អ៊ុយ យោគំណន ការិយាល័យទី១ អគ្គមេបញ្ជាការ ជាសមាជិក

IV–<u>អនុគណៈកម្មការទី ៤ ទទួលបន្ទុកត្រួតពិនិត្យចំនួននាយទាហាន យោធភូមិភាគទី ៤</u>

<u>រួមមាន</u> ÷

១–ឯកឧត្តម ឧត្តមសេនិយឯក មាស សុភា នាយរងអគ្គសេនាធិការ ជាប្រធាន

២–លោក ឧត្តមសេនិយទោ ចាន់ សារឿន មេបញ្ជាការយោធភូមិភាគទី៤ ជាអនុប្រធាន

៣–លោក ឧត្តមសេនិយត្រី ម៉ុខ សំផន នាយក នាយកដ្ឋានថវិកា ជាអនុប្រធាន

៤–លោក វរសេនិយឯក ស៊ើក ផៃ នាយករងទីចាត់ការបុគ្គលិកអគ្គមេបញ្ជាការ ជាសមាជិកអចិន្ត្រៃយ៍

៥–លោក វរសេនិយទោ សៅ ផល្លា ទីចាត់ការបុគ្គលិក អគ្គមេបញ្ជាការ ជាសមាជិក

៦–លោក វរសេនិយត្រី គេត រួន នាយកដ្ឋានបុគ្គលិក ជាសមាជិក

៧–លោក វរសេនិយត្រី អ៊ូច សារឿន អធិការកិច្ច អគ្គសេនាធិការ ជាសមាជិក

៨–លោក អនុសេនិយឯក គឹម យុន នាយកដ្ឋានអធិការកិច្ច ជាសមាជិក

៩–លោក អនុសេនិយទោ អ៊ឹត ម៉ាច ការិយាល័យទី ១ អគ្គសេនាធិការ ជាសមាជិក

១០–លោក អនុសេនិយទោ ចុន សែ អធិការកិច្ច អគ្គមេបញ្ជាការ ជាសមាជិក

V–<u>អនុគណៈកម្មការទី ៥ ទទួលបន្ទុកត្រួតពិនិត្យចំនួននាយទាហាន យោធភូមិភាគទី ៥</u>

<u>រួមមាន</u> ÷

១–ឯកឧត្តម ឧត្តមសេនិយឯក ញឹក ប៊ុនឆៃ នាយរងអគ្គសេនាធិការ ជាប្រធាន

២–លោក ឧត្តមសេនីយទោ ទ៊ិន ស៊ីដារ៉េ មេបញ្ជាការយោធភូមិភាគទី ៥ ជាអនុប្រធាន

៣–លោក ឧត្តមសេនីយត្រី ម៉ក់ សារ៉ុន នាយការិយាល័យទី៤អគ្គសេនាធិការ ជាអនុប្រធាន

៤–លោក វរសេនីយទោ ផន សារឿន ទីចាត់ការបុគ្គលិក អគ្គមេបញ្ជាការ ជាសមាជិកអចិន្ត្រៃយ៍

៥–លោក វរសេនីយត្រី សុខ ម៉ុនថន នាយកដ្ឋាន បុគ្គលិក ជាសមាជិក

៦–លោក វរសេនីយទោ ទ៊ិត ជី នាយកដ្ឋានអធិការកិច្ច ជាសមាជិក

៧–លោក វរសេនីយត្រី ឆ្លុយ ចំរើន ការិយាល័យទី ១ អគ្គសេនាធិការ ជាសមាជិក

៨–លោក វរសេនីយត្រី ដាវ ហុងសេង អធិការកិច្ចអគ្គសេនាធិការ ជាសមាជិក

៩–លោក វរសេនីយត្រី ញៀប ចិន្តាសក្តិ អធិការកិច្ច អគ្គមេបញ្ជាការ ជាសមាជិក

VI–អនុគណៈកម្មការទី ៦ ទទួលបន្ទុកត្រួតពិនិត្យចំនួនទាហាន យោធភូមិភាគពិសេស

រួមមាន ÷

១–លោក ឧត្តមសេនីយទោ ព្រហ្ម ឌិន មេបញ្ជាការយោធភូមិភាគពិសេស ជាប្រធាន

២–លោក ឧត្តមសេនីយត្រី លី យីម៉ុន នាយក នាយកដ្ឋានអធិការកិច្ច ជាអនុប្រធាន

៣–លោក ឧត្តមសេនីយត្រី ពុត សំអោក នាយករងទីចាត់ការបុគ្គលិកអគ្គមេបញ្ជាការ ជាអនុប្រធាន

៤–លោក វរសេនីយឯក ជា ខេមរា នាយរងការិយាល័យទី១ អគ្គសេនាធិការ ជាសមាជិក អចិន្ត្រៃយ៍

៥–លោក វរសេនីយត្រី ទឹម វណ្ណារិន្ទ ទីចាត់ការបុគ្គលិក អគ្គមេបញ្ជាការ ជាសមាជិក

៦–លោក វរសេនីយត្រី ឡេង សុផុន នាយកដ្ឋានបុគ្គលិក ជាសមាជិក

៧–លោក វរសេនីយត្រី ចាន់ បុរិន នាយកដ្ឋានអធិការកិច្ច ជាសមាជិក

៨–លោក វរសេនីយត្រី ថោង វណ្ណនី អធិការកិច្ច អគ្គសេនាធិការ ជាសមាជិក

៩–លោក វរសេនីយត្រី ហ៊ុះ សៀងលីម អធិការកិច្ច អគ្គមេបញ្ជាការ ជាសមាជិក

១០–លោក អនុសេនីយឯក ចាន់ នន់វិទ្យា ការិយាល័យទី ១ អគ្គសេនាធិការ ជាសមាជិក

VII–អនុគណៈកម្មការទី៧ ទទួលបន្ទុកត្រួតពិនិត្យចំនួនទាហាន និង កូន ស្ថាប័ន កងឯកភាពចំណុះផ្ទាល់អគ្គមេបញ្ជាការក្រសួងការពារជាតិ និង អគ្គសេនាធិការ រួមមាន ÷

១–លោក ឧត្តមសេនីយត្រី	**ម៉ម សុផារត**	នាយករងខុទ្ទកាល័យអគ្គមេបញ្ជាការ	ជាប្រធាន
២–លោក វរសេនីយឯក	**មុំ សោភ័ណ្ឌ**	នាយរងអធិការកិច្ច អគ្គសេនាធិការ	ជាអនុប្រធាន
៣–លោក វរសេនីយឯក	**ញឹក ប៊ុនឡី**	នាយករង នាយកដ្ឋានអធិការកិច្ច	ជាអនុប្រធាន
៤–លោក វរសេនីយឯក	**អ៊ី សារុំ**	នាយក្រុមហិរញ្ញវត្ថុ អគ្គសេនាធិការ	ជាអនុប្រធាន
៥–លោក វរសេនីយឯក	**សុត ឌុទ្ធី**	ទីចាត់ការបុគ្គលិកអគ្គមេបញ្ជាការ	ជាសមាជិកអចិន្ត្រៃយ៍
៦–លោក វរសេនីយឯក	**ស៊ិន គីមស៊ន**	អធិការកិច្ច អគ្គមេបញ្ជាការ	ជាសមាជិក
៧–លោក វរសេនីយទោ	**ប៊ុល ឈឿន**	ទីចាត់ការបុគ្គលិក អគ្គមេបញ្ជាការ	ជាសមាជិក
៨–លោក វរសេនីយទោ	**ហ្វាប សារី**	អធិការកិច្ច អគ្គសេនាធិការ	ជាសមាជិក
៩–លោក វរសេនីយត្រី	**គុជ វណ្ណារ៉ា**	ខុទ្ទកាល័យ អគ្គមេបញ្ជាការ	ជាសមាជិក
១០–លោក វរសេនីយត្រី	**កែ ប៊ុន្នី**	នាយកដ្ឋានបុគ្គលិក	ជាសមាជិក
១១–លោក វរសេនីយត្រី	**ឈរ សុខុម**	នាយកដ្ឋានអធិការកិច្ច	ជាសមាជិក
១២–លោក អនុសេនីយទោ	**ថេម ណារឫទ្ធិ**	ការិយាល័យទី ១ អគ្គសេនាធិការ	ជាសមាជិក

ប្រការ ៣ : ភារកិច្ច និង សិទ្ធិរបស់គណៈកម្មការ និង អនុគណៈកម្មការ រួមមាន ÷

- ផ្សព្វផ្សាយអោយបានយល់ជ្រួតជ្រាបនូវគោលបំណង និង សំណូមពរ ខ្លឹមសារ និងវិធានការអនុវត្តន៍ការងារត្រួតពិនិត្យចំនួនទាហាន និងកូនដល់គ្រប់កងឯកភាព និង សមាសភាពដែល មានការពាក់ព័ន្ធ
- ធ្វើផែនការ និង កម្មវិធីអោយបានច្បាស់លាស់ ក្នុងការចាត់តាំងអនុវត្តន៍
- ណែនាំ ដាស់តឿន និង ដំណើរការត្រួតពិនិត្យទាន់ពេលវេលា ត្រឹមត្រូវច្បាស់លាស់រាល់ជំហានទីមួយ ៗ
- ចុះត្រួតពិនិត្យជាក់ស្តែង ដល់គ្រប់កងឯកភាព មូលដ្ឋានថ្នាក់វរសេនាតូចកងអនុសេនាធំ
- អនុគណៈកម្មការត្រួតពិនិត្យតាមទិស មានសិទ្ធិស្នើកាត់ចំនួនទាហាន និងកូនដែលមិនពិតប្រាកដ និង មានសិទ្ធិដោះស្រាយនូវហេតុការ ដែលកើតមានឡើង ពាក់

ពិនិត្យដល់ការងារត្រួតពិនិត្យ ចំនួនទាហាន និង កូនដោយផ្អែកតាមសេចក្តី ណែនាំស្តីពីការងារគ្រប់គ្រងចំនួនទាហានលេខ ១៩៧.៩៥ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ការិយាល័យទី ១ អគ្គសេនាធិការ ។

ប្រការ ៤ : ពេលវេលាចាត់តាំងអនុវត្តន៍ការងារត្រួតពិនិត្យចំនួនទាហាន និង កូន ទូទាំងកងយោធពលខេមរភូមិន្ទ ត្រូវចាប់ផ្តើមនៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ជាកំហិត និង ត្រូវបូកសរុបលទ្ធផលនៃ ការត្រួតពិនិត្យចំនួនទាហាន និង កូន ថ្វាយ និង ជូនសហនាយករដ្ឋមន្ត្រីអោយបានមុនថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

ដោយឡែកជារៀងរាល់ថ្ងៃក៏ត្រូវរាយការណ៍ថ្វាយ និង ជូនសហនាយករដ្ឋមន្ត្រី នូវលទ្ធផលអនុវត្តន៍ជាក់ស្តែងតាមជំហាន និង តាមទិសនីមួយ ៗ ។

ប្រការ ៥ : គ្រប់យោធភូមិភាគ កងពល តំបន់ប្រតិបត្តិការសឹករង ស្ថាប័ន និងកងឯកភាពចំណុះផ្ទាល់ អគ្គមេបញ្ជាការក្រសួងការពារជាតិ អគ្គសេនាធិការ ព្រមទាំងអស់លោកដែលមានឈ្មោះក្នុងប្រការ ២ ត្រូវអនុវត្តន៍អោយបានម៉ឺងម៉ាត់ និង មានប្រសិទ្ធភាពខ្ពស់ នូវសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III-ការងារបណ្តាក្រសួង

១-ពីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១០៤ សហវ.ប្រក.ប

ស្តីពីការតែងតាំងមន្ត្រីរាជការ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- យោងតាមព្រះឣ្យជបញ្ជាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ តាមរយៈលិខិតរបស់ខុទ្ទកាល័យសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ លេខ ៨៩៥ ខុទ្ទ.៩៥ ចុះថ្ងៃទី ១៥ មិថុនា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១. តែងតាំងលោក **ឯម យិនចរ** មន្ត្រីគយនិងរដ្ឋាករ ជានាយករងទីចាត់ការគយនិងរដ្ឋាករ ។

មាត្រា ២. នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក នាយកទីចាត់ការគយនិងរដ្ឋាករ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចក្នុងមាត្រា ១ ខាងលើត្រូវទទួលបន្ទុក អនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១២ ប្រក.សហវ.គរ

ស្តីពីការតែងតាំងនិងផ្ទេរភារកិច្ច មន្ត្រីគយនិងរដ្ឋាករ

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញលិខិតខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ លេខ ៨៩៥ ខុទ្ទ.៩៥ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥
- បានឃើញតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សំរេច

ប្រការ ១ : តែងតាំងលោក **មិរាល ខូច** មន្ត្រីគយនិងរដ្ឋាករ ជាប្រធានការិយាល័យគយ និង រដ្ឋាករ ពោធិចិនតុង ។

ប្រការ ២ : ផ្ទេរភារកិច្ចលោក **អ៊ុយ សារិន** ពីប្រធានការិយាល័យគយនិងរដ្ឋាករពោធិចិនតុង មកជាប្រធានការិយាល័យត្រួតពិនិត្យ នៃទីចាត់ការគយនិងរដ្ឋាករ ។

ប្រការ ៣ : ផ្ទេរភារកិច្ចលោក **គង់ សុផន** ពីអនុប្រធានការិយាល័យគយនិងរដ្ឋាករពោធិចិនតុង មក ជាអនុប្រធានសាខាទីចាត់ការគយនិងរដ្ឋាករ ខេត្តស្វាយរៀង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក នាយកទីចាត់ការគយ និង រដ្ឋាករ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ប្រការ២ និងប្រការ៣ ខាងលើ ត្រូវ ទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខានិងត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣០១ ប្រក. សហវ.ថ

ស្តីពីការបង្វែរឥណទាន

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ. ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងមហាផ្ទៃលេខ ១៩០១ លស. ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងថវិការបស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ.	
១១	០១	១០		<u>ការបង្វែរពីជំពូក ១១</u> ចំណាយឯកសណ្ឋាន	១៥.០០០.០០០		<u>៦០០.០០០</u> ៦០០.០០០	១៤.៤០០.០០០
១១	០១	១៤	០៥	<u>ផលប្រយោជន៍ជំពូក១១</u> ផ្លាកសញ្ញានិងសក្តិ	៤០០.០០០	<u>៥០០.០០០</u> ៥០០.០០០		៩០០.០០០

ប្រការ ២ : ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

នាយ ម៉ន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣០៥ ប្រក.សហវ.ថ

ស្តីអំពីការបង្វែរឥណទាន

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ១០ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ. ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងមហាផ្ទៃលេខ១០១១ លស. ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				<u>ការបង្វែរពីជំពូក ១១</u>			<u>៧០.០០០</u>	
១១	០២	០២	០១	សោហ៊ុយដឹកជញ្ជូន	៨៣.២០៦	–	៥០.០០០	៣៣.២០៦
១១	០២	០២	០២	សោហ៊ុយបេសកកម្ម	៤២.១០០		២០.០០០	២២.១០០
				<u>ផ្ទេរប្រយោជន៍ជំពូក១១</u>		<u>៧០.០០០</u>	–	
១១	០១	០២		ចលនវត្ថុ សំភារៈ	៨១.០០០	៧០,០០០		១៥១.០០០

ប្រការ ២ : ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកទទួលបន្ទុកក្នុងការអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ឆាយ ឋន

* * *

២-និស្តិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ : ៦៥០ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ហ៊ិន ទ៉ាន** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២១០០២៧ ក.ណ ចុះថ្ងៃទី ១៤-១២-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែកតាដួង ឃុំ ព្រែកថ្មី ស្រុក កោះធំ ខេត្ត កណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ នៅក្នុងទី តាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក **ហ៊ិន ទ៉ាន** ត្រូវចាប់ផ្តើម ដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៥១ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី អ៊ុំ សុគន្ធា ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៨៦៣៥៤ ភ.៣ ចុះថ្ងៃទី ១៤-៣-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦០

អឺ២ ផ្លូវលេខ ២១៧ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកដំណើរការឡផលិតនំប៉័ង នៅក្នុងទីតាំងក្រុមទី ៥ ភូមិ ត្រពាំងអង្គ ឃុំរការក្រៅ ទីរួមខេត្តតាកែវ ខេត្តតាកែវ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផល គ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៥៣ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ជុក ឆ៊ាត** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៩៦០៣០ ក.ណ ចុះថ្ងៃទី ០៣–៩–៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ត្រពាំងចក ឃុំ ថ្មី ស្រុក កណ្តាលស្ទឹង ខេត្ត កណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទី តាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក **ជុក ឆ៊ាត** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៥៤ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយមូលដ្ឋានផលិតទឹកកកដើម ដែលមានលោក **គុយ គង់** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០២០១៩០ ស្វ.រ ចុះថ្ងៃទី ១៨–៧–៨៦ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ២ ភូមិ ទួលអំពិល ឃុំច្រកម្ទេស ស្រុកស្វាយទាប ខេត្តស្វាយរៀង បើកដំណើរការផលិតកម្ម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ : ៦៥៨ ផក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊ុច ខៃ** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៣៦៩៥ កស្គ ចុះថ្ងៃទី ៣១–១២–៨៥ អាសយដ្ឋានបច្ចុប្បន្ន ក្រុមទី ១ ភូមិ ត្រពាំងព្រះ ឃុំ កណ្តោលជុំ ស្រុក ច្បារមន ខេត្តកំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ នៅក្នុងទីតាំង ដូចអាសយដ្ឋាន ខាងលើ ។

ប្រការ ២ : លោក **ស៊ុច ខៃ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៥៩ ផក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីន ផលិតទឹកកកដើម ដែលមានលោក **សេខ សុធា** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០១២៦៦៤ ក.ព ចុះថ្ងៃទី ១៤–០២–៨៧ ជា ប្រធាន អាសយដ្ឋានបច្ចុប្បន្ន ភូមិ ត្រពាំងធំ ឃុំ ត្រពាំងសង្កែ ស្រុកកំពត ខេត្ត កំពត ។ បើកដំណើរការផលិតកម្មនៅក្នុងទីតាំង ភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកកំពត ខេត្តកំពត ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស

ច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦០ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ុន ហឿន** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៦៤៤៨ ក.ពក ចុះថ្ងៃទី ០៣–០១–៨៧ អាស័យដ្ឋាន បច្ចុប្បន្ន ភូមិ រទាំង ឃុំ ភូមិធំ ស្រុក គៀនស្វាយ ខេត្ត កណ្តាល បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១២ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **អ៊ុន ហឿន** ត្រូវចាប់ផ្តើម ដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុង ប្លង់ ដោយ ធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦១ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ឈុំ សុខណ្ណ** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៨១១២៤ កស្ត ចុះថ្ងៃទី ០៩–៣–៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ភ្នំដី សង្កាត់ ច្បារមន ទីរួម ខេត្ត កំពង់ស្ពឺ ខេត្ត កំពង់ស្ពឺ បន្តដំណើរ ការម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើ ពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦២ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊ុយ ម៉ាង** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៤៣៥៨៨ ភ.ព ចុះថ្ងៃទី ០៦–៣–៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២១ អែហ្វអឹ០ ផ្លូវលេខ ១៧ សង្កាត់ ផ្សារចាស់ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតនំផ្អែម « ហួរ–ហេង » នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ស៊ុយ ម៉ាង** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម នំផ្អែម សញ្ញា « រូបស្លាំង » ស្របតាមគំរូ សញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាព ប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦៣ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : អនុញ្ញាតអោយ មូលដ្ឋានផលិតទឹកកកដើម ដែលមានលោក **គីក នឹន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០១៥៩៦៤ ក.ង ចុះថ្ងៃទី ១២–៧–៨៨ ជាប្រធាន អាស័យ ដ្ឋានបច្ចុប្បន្ន ភូមិ ឈើទាល ឃុំ កំពង់ចិនត្បូង ស្រុក ស្ទោង ខេត្ត កំពង់ធំ បើកដំណើរការ ផលិតកម្ម នៅក្នុងទី តាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦៤ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក ឡាំ អ៊ឹម ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣០០០៣១ ភ.ព ចុះថ្ងៃទី ១០-១២-៩០ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៥ ភូមិ វាល ឃុំ សាន់គរ ស្រុក កំពង់ស្វាយ ខេត្ត កំពង់ធំ បើកដំណើរការមូលដ្ឋានផលិតទឹកកក ដើម នៅក្នុងទីតាំង ដូច អាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦៥ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី ឡៅ ហៀង ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៤៩៤៧៤ កស្ត. ចុះថ្ងៃទី ០១-៧-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្រសាំងជីមៃ ឃុំ វាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី ឡៅ ហៀង ត្រូវចាប់ផ្តើម ដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុង ប្លង់ ដោយ ធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦៦ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ម៉ាន ខឹម ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣៦៩១៨១ ក.ណ ចុះថ្ងៃទី ០២-១២-៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ

ព្រៃកុះ ឃុំ ព្រៃកគយ ស្រុក ស្អាង ខេត្ត កណ្ដាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំង ភូមិ ចំបក់ ឃុំ សៀមរាប ស្រុក កណ្ដាលស្ទឹង ខេត្ត កណ្ដាល ។

ប្រការ ២ : លោក **ម៉ាន ទឹម** ត្រូវចាប់ផ្ដើម ដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុង ប្រការ ១ ដោយ ធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦៧ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **អ៊ុង ឡាង** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០០៣៥៣៨ កស្ក. ចុះថ្ងៃទី ២៩–១២–៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ រការធំ ឃុំ វល្លិស ស្រុក សំរោងទង ខេត្ត កំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ នៅក្នុងទីតាំង ក្រុមទី ៣ ភូមិ ផ្សារសាមគ្គី សង្កាត់ ឯករាជ្យ ទីរួមខេត្ត កំពង់ស្ពឺ ខេត្ត កំពង់ស្ពឺ ។

ប្រការ ២ : អ្នកស្រី **អ៊ុង ឡាង** ត្រូវចាប់ផ្ដើម ដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុង ប្រការ ១ ដោយ ធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦៨ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុនសុរាតារក្បាលពោធិ « ថៃ ផេងអ៊ា » ដែលមានលោក **ហុង ស្រ៊ុន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៨៩៤១៤ ភ.ព ចុះថ្ងៃទី ២២-៨-៨៨ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិ សៃវ៉ា ឃុំ ព្រៃផ្តៅ ស្រុក ព្រៃកប្បាស ខេត្ត តាកែវ បន្តដំណើរការ ផលិតកម្ម នៅក្នុងទីតាំង ភូមិ ក្បាលពោធិ ឃុំ សំបួរ ស្រុក ទ្រាំង ខេត្ត តាកែវ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៦៩ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក **ហេង សុខ** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២២៨៧២៦ ភ.ព ចុះថ្ងៃទី ១៤-៥-៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣២៨ ផ្លូវលេខ ៦៣ ក្រុមទី ៦៥ សង្កាត់ បឹងកេងកងទី ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការ រោងជាងជួសជុលរថយន្ត នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៧០ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ១ :- អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានលោក **ឡាំ សាន់** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ផ្សារត្រាច ឃុំស្វាយ ស្រុក

សាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង បើកដំណើរការ ផលិតកម្មប្រើដោយម៉ាស៊ីនកំលាំង ២០សេះ នៅក្នុង ទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក **ឡាំ សានី** ត្រូវចាប់ផ្តើម ដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូច បានកំណត់ក្នុង ប្លង់ ដោយ ធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស ច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៦៧២ បល.ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥
ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំតំរោងការ តាំងពិព័រណ៍ WORLDTECH'95 នៅប្រទេសថៃឡង់ដ៍

* * *

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល កម្ពុជា

– បានឃើញលិខិតលេខ ១០៧១ សជណ.ផក ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ ទីស្តីការរដ្ឋមន្ត្រី ស្តីពីការប្រគល់ភារកិច្ចអោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ទទួលខុសត្រូវរួមក្នុង ការចូលរួមតាំងពិព័រណ៍ WORLDTECH'95 នៅប្រទេសថៃ ឡង់ដ៍

– បានឃើញលិខិតលេខ ៤៩៤០ កសក.ផសប ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩៥ របស់ក្រសួង កសិកម្មរុក្ខាប្រមាញ់ និង នេសាទ

– បានឃើញលិខិតលេខ ៧៨៤ កទច.របស់ក្រសួងទេសចរណ៍

– ពិនិត្យសំណូមពរតាររងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំតំរោងការតាំងពិព័រណ៍ WORLDTECH'95 នៅប្រទេសថៃឡង់ដ៍ ដែលមានសមាសភាពដូចខាងក្រោម :

១– ឯកឧត្តម **ហ៊ុល លីម** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ប្រធាន
២– ឯកឧត្តម **លឹម គានហោ** តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន
៣– លោក **ង៉ាត់ សុខុម** តំណាងក្រសួងទេសចរណ៍ អនុប្រធាន
៤– លោក **ម៉េង ណារ៉ាឌុន** តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក អចិន្ត្រៃយ៍
៥– លោក **ខួន នៅ** តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក
៦– លោក **ហូ វិចិត្រ** តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក
៧– លោក **សុន សេងហួត** តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក
៨– លោក **មាន បូរ៉ា** តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សមាជិក
៩– លោក **ម៉េច សុវណ្ណារ៉ាណូ** តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សមាជិក
១០– លោក **ឃុន ពៅ** តំណាងក្រសួងទេសចរណ៍ សមាជិក
១១– លោក **យ៉ិន ស៊ីផេង** តំណាងក្រសួងទេសចរណ៍ សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

- ជ្រើសរើស ស្វែងរកសំភារៈ ផលិតផល ដែលមានគុណភាពប្រណិត និងមានលក្ខណៈសមស្រប សំរាប់ការតាំងពិព័រណ៍
- រៀបចំលើកតំរោងថវិកាចំណាយ សំរាប់បំរើអោយការងារតាំងពិព័រណ៍
- ធ្វើរបាយការណ៍ជូនក្រសួង និងទីស្តីការគណៈរដ្ឋមន្ត្រី ពីលទ្ធផលការងារដែលអនុវត្តបាន

ប្រការ ៣ : សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំ និងធ្វើការងារ តាមការអញ្ជើញ និង ការ ណែនាំរបស់ប្រធាន ។

ប្រការ ៤ : លោកប្រធានមន្ទីរ លោកប្រធានគ្រប់នាយកដ្ឋានពាក់ព័ន្ធ និងអស់លោកដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌរៀងៗ ខ្លួនតាមប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរៈ

* * *

៣ -ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៨២/៩៥ ពម.ប្រក

អនុញ្ញាតអោយទស្សនាវដ្ដី «សមាគមទន្តពេទ្យ» បោះពុម្ពផ្សាយ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសាន បញ្ញត្តិ មាត្រា ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មានដែលរដ្ឋសភានៃរដ្ឋកម្ពុជា អនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតឆ្លើយតបលេខ ៥៥៣សជណ.ផក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ១៩៩៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញសំណើរបស់លោកទន្តបណ្ឌិត ហែម ឈិន ចុះថ្ងៃទី ២៣ មិថុនា ១៩៩៥ ដើម្បីបោះពុម្ពផ្សាយទស្សនាវដ្ដីសមាគមទន្តពេទ្យ កម្ពុជា

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយទស្សនាវដ្តី «សមាគមទន្តពេទ្យ កម្ពុជា » ដែលមានលោកទន្តបណ្ឌិត **ខែម ឈិន** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២: ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣: គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកសារពតិមាន និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន [illegible]ទាំង[illegible]រាល់ទស្ស[illegible]ដ្តីចំនួន ១៥ ច្បាប់ រៀងរាល់លេខ ចេញផ្សាយមកតំកល់ទុកជាឯកសារ[illegible]ស្សួងពតិមាន ។

ប្រការ ៤: លោក **ខែម ឈិន** ចាងហ្វាងការផ្សាយទស្ស[illegible]ដ្ត «សមាគមទន្តពេទ្យកម្ពុជា» និងនាយកដ្ឋាន មណ្ឌលពតិមាន នៃក្រសួងពតិមានត្រូវអ[illegible]វត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៨៣/៩៥ ពម.ប្រក

អនុញ្ញាតអោយលោក សាយ ឃាន ផ្ទេរឋានៈចាងហ្វាង

ការផ្សាយកាសែត «ខ្មែរអង្គរ» ជូនលោក កែវ ប្រាក់សុវណ្ណ

រដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសាន បញ្ញត្តិ មាត្រា ទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពតិមាន ដែលរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័តនាសម័យប្រជុំវិសាមញ្ញ

ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១

- បានឃើញប្រកាសអនុញ្ញាតលេខ ១៥៨-៩៥ ពម.ប្រក ចុះថ្ងៃទី ២៤-៧-១៩៩៥ អោយកាសែត «ខ្មែរអង្គរ»ចេញផ្សាយដោយមានលោក **សាយ ឃាន** ជាចាងហ្វាងការផ្សាយ
- បានឃើញលិខិតស្នើសុំផ្ទេរឋានៈចាងហ្វាងការផ្សាយ ចុះថ្ងៃទី ២៨-៧-១៩៩៥ របស់លោក **សាយ ឃាន**

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **សាយ ឃាន** ផ្ទេរឋានៈចាងហ្វាងការផ្សាយកាសែត «ខ្មែរអង្គរ» ជូនលោក **កែវ ឬទ្ធាក់សុវណ្ណពេជ្រមុន្នីរត្ន** វិញ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣: គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងស្នើប្រគល់កាសែតចំនួន ១៥ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤: លោក **កែវ ឬទ្ធាក់សុវណ្ណពេជ្រមុន្នីរត្ន** ចាងហ្វាងការផ្សាយកាសែត «ខ្មែរអង្គរ» និងនាយកដ្ឋាន មណ្ឌលពត៌មាននៃក្រសួងពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ :ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៨៤/៩៥ ពម.ប្រក

អនុញ្ញាតអោយកាសែត «សំលេងនិស្សិត» បោះពុម្ពផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រា ទី ១៣៩

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ដែលរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតស្នើសុំរបស់ អ្នកស្រី **ជួន រានី** ម្ចាស់ហាងការផ្សាយកាសែត «សម្លេងនិស្សិត» ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយ កាសែត «សម្លេងនិស្សិត» បោះពុម្ពផ្សាយ ដែលមានអ្នកស្រី **ជួន រានី** ជាម្ចាស់ហាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣: គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងស្នើប្រគល់កាសែតចំនួន ១៥ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤: អ្នកស្រី **ជួន រានី** ម្ចាស់ហាងការផ្សាយកាសែត «សម្លេងនិស្សិត» និងនាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៨៥/៩៥ ពម.ប្រក

អនុញ្ញាតអោយលោក ជា សុង ចាងហ្វាងការផ្សាយកាសែត «សំលេងពលរដ្ឋខ្មែរ» ចេញផ្សាយជាភាសាចិន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រា ទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មានត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជា អនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញច្បាប់អនុញ្ញាតលេខ ៩៥២.ឃ.ព. ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៣ របស់ក្រសួងឃោសនាការនិងពត៌មាន
- បានឃើញលិខិតស្នើលេខ ១៦២ .ស.ព.ខ. ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៥ របស់លោក ជា សុង ចាងហ្វាងការផ្សាយពត៌មាន «សម្លេងពលរដ្ឋខ្មែរ»

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ជា សុង** ចាងហ្វាងការផ្សាយកាសែត «សម្លេងពលរដ្ឋខ្មែរ» ចេញផ្សាយជាភាសា ចិនប្រចាំថ្ងៃថែមទៀត ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣: គោរពតាមច្បាប់សារពត៌មាន គោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតី ទទួលខុសត្រូវ ខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និងស្នើប្រគល់កាសែតចំនួន ១៥ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤: លោក **ជា សុង** ចាងហ្វាងការផ្សាយកាសែត «សម្លេងពលរដ្ឋខ្មែរ» ជាភាសាចិន និងនាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មានត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៨៧/៩៥ ពម.ប្រក

អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ «អប្សរ៉ាម៉ា »ចេញផ្សាយជាភាសាខ្មែរ

និង ភាសាបារាំង

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រា ទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័ត នាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញលិខិត ស្នើសុំអនុញ្ញាតិបើកទស្សនាវដ្តីឈ្មោះ «អប្សរ៉ាម៉ា» របស់លោក **គីម ទិមល** ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ «អប្សរ៉ាម៉ា» ចេញផ្សាយជា ភាសាខ្មែរ និង ភាសាបារាំង ដោយមានលោក **គីម ទិមល** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣: គោរពតាមច្បាប់សារពត៌មាន គោលការណ៍ក្រមសីលធម៌ អ្នកកាសែត និងឈរលើស្មារតី ទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និងផ្ញើប្រគល់ទស្សនាវដ្តី ចំនួន ១៥ ច្បាប់ រៀងរាល់លេខ ចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤: លោក **គីម ទិមល** ជាចាងហ្វាងការផ្សាយទស្សនាវដ្តី «អប្សារ៉ាម៉ា» និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៨៨/៩៥ ពម.ប្រក

ស្តីពី ការយល់ព្រមទទួលស្គាល់ មន្ត្រី រាជការ

* * *

- បានឃើញ ព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងសំណើលេខ ៣០២ ពម ៩៥ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ក្រសួងពត៌មាន
- យោងលិខិត លេខ ៩៩ បលៈ៩៥ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៥ របស់អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា
- យោងសេចក្តីសំរេច លេខ ០៩ សសរ.៩៥ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៥ របស់អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា

សំរេច

ប្រការ ១ : យល់ព្រមនិងទទួលស្គាល់ លោក **ទិត សមប្រាជ្ញា** អនុប្រធានការិយាល័យ រដ្ឋបាល អគ្គនាយកដ្ឋានវិទ្យុជាតិ អោយមកបំរើការងារនៅអគ្គាធិការដ្ឋាន នៃ ក្រសួងពត៌មាន ។

ប្រការ ២: ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន អគ្គនាយកដ្ឋានវិទ្យុជាតិ ត្រូវផ្ទេរមកទីស្តីការរដ្ឋមន្ត្រី ដោយគិតចាប់ពីថ្ងៃទី ០១ ខែ កញ្ញា នេះតទៅ ។

ប្រការ ៣: អគ្គាធិការដ្ឋានត្រូវរៀបចំសំរួលបែងចែកភារកិច្ចជូន លោក **ឡឹក សមប្រាជ្ញា** អោយបានសមស្រប ។

ប្រការ ៤: អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នាយកដ្ឋានបុគ្គលិករដ្ឋបាល នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ និង សាមីខ្លួន មានភារៈអនុវត្តន៍តាមប្រកាសចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៩៥ សក.ដជ

ស្តីពីការទទួលស្គាល់គោកហ៊ុនបន្ថយនិងបន្ថែមរបស់រដ្ឋ នៅក្នុងក្រុមហ៊ុនកម្ពុជានាវាដឹកជញ្ជូន «កាំពង់ស៊ីប»

* * *

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤.៩០ ចុះថ្ងៃទី ៣១-១០-១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញលិខិតលេខ ២២៤/ សជណ.កប ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ៤២/សសរ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៣ របស់រាជរដ្ឋាភិបាល
- បានឃើញសេចក្តីសំរេចលេខ ១៤/៩៤ កធស ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងធម្មការនិងសាសនា ស្តីពីការប្រគល់ដីរោងជាងសំបកនាវា ព្រែកញ្ញៅ ជូនទៅវត្តជោតិមង្គល ឃុំព្រែកញ្ញៅ ស្រុក ពញាឮ ខេត្ត កណ្តាល ដើម្បីគ្រប់គ្រង និងចាត់ចែងតាមបទបញ្ញត្តិ និងពុទ្ធបញ្ញត្តិនៃព្រះពុទ្ធសាសនា
- បានឃើញលិខិតលេខ ៥២១/សក.កសន ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ និងចំណារឯកភាពរបស់ឯកឧត្តមអភិបាលទីក្រុងព្រះសីហនុ លេខ ៤៣០ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- បានឃើញលិខិត ប្រគល់ទីតាំងអ្វូទូកស្ទឹងហាវ លេខ ០១២/សក.កសន ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៥ របស់មន្ទីរសាធារណការនិងដឹកជញ្ជូន ក្រុងព្រះសីហនុទៅអោយក្រុមហ៊ុនកម្ពុជានាវាដឹកជញ្ជូន «កាំត្រង់ស៊ីប»
- បានឃើញកំណត់ហេតុ ស្តីពីការត្រួតពិនិត្យវាយតំលៃសារជាថ្មីនូវអ្វូស្ទឹងហាវ ក្រុងព្រះសីហនុ ចុះថ្ងៃទី ១៦-៥-១៩៩៥
- បានឃើញលិខិត ១៣០៨/សហវ.ហ ចុះថ្ងៃទី ០៣-៨-១៩៩៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុនកម្ពុជានាវាដឹកជញ្ជូន ប្តូរទីតាំងអ្វូជួសជុលនាវា ពីរោងជាងព្រែកញ្ញៅ ស្រុកពញាឮ ខេត្ត កណ្តាល ទៅនៅអ្វូជួសជុលទូកនៅខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ។

ប្រការ ២: ទទួលស្គាល់ភាគហ៊ុនបន្ថយ និង ភាគហ៊ុនបន្ថែមរបស់រដ្ឋ នៅក្នុងក្រុមហ៊ុនកម្ពុជានាវាដឹក ជញ្ជូន ដូចមានតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសនេះ ។

ប្រការ ៣: លោកនាយកខុទ្ទកាល័យ–អគ្គនាយក–អគ្គនាយកដ្ឋានដឹកជញ្ជូន និង លោកប្រធានក្រុមហ៊ុនកម្ពុជានាវាដឹកជញ្ជូន ត្រូវទទួលបន្ទុកតាមភារកិច្ចរៀងៗ ខ្លួនអនុវត្តន៍ប្រកាសនេះ អោយមានប្រសិទ្ធភាព ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គ្រាំ អ៊ុទគីក

* * *

<u>តារាងឧបសម្ព័ន្ធភ្ជាប់និងប្រកាសលេខ ៥៩៩ សក ចុះថ្ងៃទី ២១–៨–១៩៩៥</u>

<u>ស្តីពីការទទួលស្គាល់ភាគហ៊ុនបន្ថយរបស់រដ្ឋ នៅក្នុងក្រុមហ៊ុនកម្ពុជា</u>

<u>នាវាដឹកជញ្ជូន « កាំត្រង់ស៊ីប »</u>

ល.រ	ឈ្មោះទ្រព្យសម្បត្តិ	តំលៃជាប្រាក់រៀល	គិតជាប្រាក់ដុល្លារ អាមេរិក
	I–<u>ភាគហ៊ុនបន្ថយ</u>		
១	<u>ផ្ទៃដីរោងជាងព្រែកព្នៅ</u>		
	–ផ្ទៃដីអាគារ ៥ខ្នង ១០០× ៤០ = ៤.០០០ម២		
	–ផ្ទៃដីមុខអាគារ ៥ខ្នង ១០០× ៦០ = ៦.០០០ម២		
	–ផ្ទៃដីខាងជើងរោងជាង ១០០×១០០ =<u>១០.០០០ម២</u>		
	សរុប = <u>២០.០០០ម២</u>	<u>១៣៦.៨០០.០០០៖០០</u>	៦០.០០០ ដុល្លារ
២	អាគាររោងជាងព្រែកព្នៅ	២៦.៦២៧.៤០០៖០០	
៣	–គ្រឿយ ៥ គោន	២០.២៣២៖០០	
៤	–សារីយោ	៤.៩២១.១២៨៖០០	
៥	–ផ្លូវដែក	១០.២៨០.១០៦៖០០	
	សរុប	៤១.៨៤៨.៨៦៦៖០០	១៨.៣៥៤,$៧៦
	សរុបទាំងអស់	១៧៨.៦៤៨.៨៦៦៖០០	៧៨.៣៥៤,$៧៦
	(យោងតាមលិខិតក្រសួងហិរញ្ញវត្ថុលេខ ១៨០/កហវ ចុះថ្ងៃទី ២៣–០២–១៩៩៣) ។		
	II)–<u>ភាគហ៊ុនបន្ថែម</u>		
១	–ផ្ទៃដីទីតាំងអ្នរទូកស្ទឹងហាវ២៩.៧៣០ម២តំលៃ ៤៧.៨៦៥.៣០០៖០០×២,៩	១៣៨.៨០៩.៣៧០៖០០	៦០.៨៨១,២៩ ដុល្លារ

២	-អាគារ ២ខ្នង ផ្ទៃ ១១១.២៤ម២ តំលៃ ៤.៦០៥.៣៣៦៖០០×២,៩	១៣.៣៥៥.៤៧៤៖០០	៥.៨៥៧,៦៦ ដុល្លារ
៣	-ដែកវ៉ៃ ៨៧៨,៤៦ម តំលៃ ៨.៧៨៤.៦០០៖០០×២.៩	២៥.៤៧៥.៣៤០៖០០	១១.១៧៣,៣៩ ដុល្លារ
៤	-រទេសអូស មួយ គ្រឿង តំលៃ ២០០.០០០៖០០ ត្រូវជា	១.០០៨.៦៨១៖០០	៤៤២,៤២ ដុល្លារ
	យោងតាមលិខិតក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុលេខ ១០៣៨ សហវ.ហ ចុះថ្ងៃទី ០៣-៨-១៩៩៥	១៧៨.៦៤៨.៨៦៦៖០០	៧៨.៣៥៤៖៧៦

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ព្រាំ អ៊ុនតឹក

* * *

៥- ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥១ប្រក.វវស.មុ

ស្តីពីការលុបឈ្មោះមន្ត្រី រាជការ

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញពាក្យសុំលាឈប់ពីការងាររបស់សាមីខ្លួន

សំរេច

មាត្រា ១ : អ្នកស្រី **ផន សុផារី** ជាបុគ្គលិកនាយកដ្ឋានសិល្បៈនិងទស្សនីយភាពត្រូវបាន អនុញ្ញាតអោយ លុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌបុគ្គលិកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដោយសុំលាឈប់ ។

មាត្រា ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានសិល្បៈ និង ទស្សនីយភាព និង អ្នកស្រី **ផន សុផារី** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្ថលេខា និងត្រា

ស៊ីសុវត្ថិ ស៊ីរីវុធ ប៉ាណរ៉ា

* * *

៦-ទីស្តីការរដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៧៩ ប.ស្ថ

ស្តីពីការដាក់អោយប្រើប្រាស់ឯកសណ្ឋាន

របស់មន្ត្រីរាជការក្រសួងគ្រប់គ្រងបរិស្ថាន

* * *

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាលេខ នស,រកត ១០–៨–១៩៩៤ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ០៦ ន,ស ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- យោងអនុក្រឹត្យលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥
- យោងលិខិតលេខ ១១៩៤ សជណ.កស ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញតំរូវការចាំបាច់របស់ក្រសួង

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន

សំរេច

ប្រការ ១ : កំណត់ឯកសណ្ឋានរបស់ អធិការ អភិបាល ភ្នាក់ងារ និងអនុរក្សបរិស្ថានមានដូចខាងក្រោម ÷

រូបភាពនិងខ្នាតឯកសណ្ឋាន :

ក–ឯកសណ្ឋានអធិការជាន់ខ្ពស់មានពីរសំរាប់គឺ :

១–អាវវ៉ារ៉ឺកបើកប៉ូលស្វា មានហោប៉ៅបួនដេរប៉ះ ហោប៉ៅពីរលើដេរបត់ផ្នត់ចំកណ្តាល គំរបរាងស្លឹកពោធិ ពីរខាងក្រោមគំរបរាងចតុកោណ កែងឡេវបួនមានរូបព្រះ សង្ខាពណ៌មាស អាវដៃវែងចុងដៃមានដាក់ឡេវបញ្ចោតបី ។

- អាវសឺមីក្នុងកខុបក្រណាត់តេតារុងពណ៌ស អាវដៃវែងមានហោប៉ៅគ្មានគំរបកាត់ស្រុងវែងដាក់ក្នុងខោ ។
- ខោជើងវែងថ្មេបង្កប់ចង្កេះតមានក្លីពីមុខ មានហោប៉ៅបី ខាងក្រោយមួយមានដេរបង្កប់គំរបរាងស្លឹកពោធិ ហោប៉ៅចំហៀងពីរដេរបង្កប់តាមថ្នេរខោសំរាប់ប្រើក្នុងពិធីបុណ្យជាតិធំៗ និងគាល់ព្រះមហាក្សត្រ ។

- ម្កុកកាស្កេតដំបូលខាងលើពណ៌អាវ ជើងម្កុកខាងក្រោមពណ៌បៃតងនៃពណ៌មាស និង ឡេវរូបព្រះសង្ខាពណ៌មាសនៅលើហាមម្កុកមានចាក់ក្បាច់ភ្ញីទេសឱនដល់ជើងម្កុកពណ៌មាស ។

២–អាវសាហារីយ៉ែនដៃខ្លីកបើក មានហោប៉ៅបួន » ពីរខាងលើដេរប៉ះគំរបរាងស្លឹកពោធិ ពីខាងក្រោមដេរយោគមកក្រៅគំរបរាងចតុកោណកែងប៊ូលស្មាខ្ទង់ជីបភ្ញីពីរ នៅចង្កេះមានក្រវាត់ជាប់អាវ ទំហំបួន ស,ម ក្បាលក្រវាត់រាងពងក្រពើមានរូបមកុដ សំរាប់ប្រើពេលបំពេញការងារ និងពិធីបុណ្យធម្មតា ។

- ខោជើងវែងថ្មេរបង្កប់ ហោប៉ៅបី ដូចចំណុច ១ គ្រទី ២ ។

ខ–ឯកសណ្ឋានអភិបាលបរិដ្ឋាន :

- អាវកាត់រាងសាហារីយ៉ែនដៃខ្លីកបើកប៊ូលស្មាមានហោប៉ៅបួន » ពីខាងលើដេរប៉ះគំរបរាងស្លឹកពោធិ ពីខាងក្រោមដេរយោគមកក្រៅគំរបរាងចតុកោណកែងប៊ូលស្មាខ្ទង់ជីបភ្ញីពីរ នៅចង្កេះគ្មានខ្សែក្រវាត់ ។
- ខោជើងវែងថ្មេរបង្កប់ហោប៉ៅបី «នារីសំពត់ហ៊ូបក្រោមក្បាលជង្គង់ផែកក្រោយ» ម្កុកកាស្កេតដំបូលលើពណ៌អាវជើងម្កុកខាងក្រោមពណ៌បៃតងនៃពណ៌មាសឡេវរូប ព្រះសង្ខាពណ៌មាស នៅលើហាមម្កុកមានច្បាច់ភ្ញីទេសឱន ។

គ–ឯកសណ្ឋានភ្នាក់ងារបរិដ្ឋាន :

- អាវកខុបមានប៊ូលស្មា ហោប៉ៅពីរដេរប៉ះមានសញ្ញាបរិដ្ឋាននៅដៃអាវខាងឆ្វេង
- ខោជើងវែងថ្មេរបង្កប់ហោប៉ៅបី » នារីសំពត់ហ៊ូបក្រោមក្បាលជង្គង់ផែក ក្រោយ
- ម្កុកហ្សុកកី មានសញ្ញាបរិដ្ឋាននៅពីមុខ ។

ឃ–ឯកសណ្ឋានអនុរក្សបរិដ្ឋាន :

- អាវកឱបមានប៊ូលស្មា ហោប៉ៅពីរដេរប៉ះមានសញ្ញាបរិដ្ឋាននៅដៃអាវខាងឆ្វេង
- ខោជើងវែងថ្មេរបង្កប់ហោប៉ៅបី » នារីសំពត់ហ៊ូបក្រោមក្បាលជង្គង់ផែក ក្រោយ
- ម្កុកហ្សុកកីស មានសញ្ញាបរិដ្ឋាននៅពីមុខ ។

ប្រការ ២ : ឯកសណ្ឋានខាងលើ អនុញ្ញាតអោយប្រើប្រាស់ សំរាប់ចូលរួមក្នុងពិធីបុណ្យជាតិ បេសកកម្មក្នុងប្រទេស និង បំពេញការងារក្នុងអង្គភាពដោយកំណត់ពណ៌តែមួយ គឺពណ៌ពងក្រសាខ្ចី ។

ប្រការ ៣: ខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ នាយកដ្ឋានចំណុះ ប្រធានមន្ទីរគ្រប់គ្រងបរិដ្ឋានខេត្ត-ក្រុង ត្រូវទទួលអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗ ខ្លួន ។

ប្រការ ៤ : ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

៧ -ទីស្តីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៧៣១ អ.ជ.ប

ស្តីពីការតែងតាំង មន្ត្រី រាជការ

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល និង ការប្រព្រឹត្តិទៅនៃ ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមតំរូវការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលមាននាមដូចខាងក្រោម អោយទទួលភារៈកិច្ចដឹកនាំតាមបណ្តាអង្គភាពនានា ចំណុះក្រសួងដូចតទៅ ÷

ក, ខុទ្ទកាល័យ :

- ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ភានុវ័ត្ត « នាយក »
- លោក អៀង គីមឡាយ « នាយ »

ខ, អគ្គាធិការដ្ឋាន :

- លោក សោម ចំនួរ៉ែម « អគ្គាធិការ »
- លោក សុក ឡៀន « អធិការ »
- លោកស្រី ស៊ីផា ឡឺបោនំរ « អធិការ »

គ, អគ្គនាយកដ្ឋាន កិច្ចការបច្ចេកទេស :

- លោក ទ្រី ម៉េង « អគ្គនាយក »
- លោក យុន ខៃត « អគ្គនាយករង »

ឃ, អគ្គនាយកដ្ឋានកិច្ចការ រដ្ឋបាល–ហិរញ្ញកិច្ច :

- លោក សួស គង់ « អគ្គនាយក »
- លោក សេង គេង « អគ្គនាយករង »

ង, នាយកដ្ឋាន រដ្ឋបាល–បុគ្គលិក :

- លោក ឯក ផា « ប្រធាន »
- លោក អ៊ុំ ប៊ុណ្ណីន « អនុប្រធាន »
- លោកស្រី ឆាន លីហួ « អនុប្រធាន »

ច, នាយកដ្ឋាន ផ្គត់ផ្គង់ ហិរញ្ញកិច្ច :

- លោក សោម សារ៉ែន « ប្រធាន »
- លោក សោម សាយ « អនុប្រធាន »
- លោក ស្វាយ រ៉ែត « អនុប្រធាន »

ឆ, នាយកដ្ឋាន ផែនការ និង ទំនាក់ទំនង :

- លោក លី ឬស « ប្រធាន »
- លោក ញៀម ផាន « អនុប្រធាន »
- លោក សៅ ឌីទ័ន្ត « អនុប្រធាន »

ផ, នាយកដ្ឋានបណ្តុះបណ្តាល និង ស្រាវជ្រាវ :

- លោក សេង ណារ៉ុង « ប្រធាន »
- លោក ម៉ុន ឈាងហេង « អនុប្រធាន »
- លោក ឈាត សំណាង « អនុប្រធាន »

ឈ, នាយកដ្ឋានអភិវឌ្ឍន៍ សហគមន៍ :

- លោក យឹម សំអឿន « ប្រធាន »
- លោក ឡុច សន « អនុប្រធាន »
- លោក គង់ សាខន « អនុប្រធាន »

ញ, នាយកដ្ឋានអភិវឌ្ឍន៍ សេដ្ឋកិច្ចជនបទ :

- លោក ពៅ យ៉ាដា « ប្រធាន »
- លោក ដាន់ សាគឿន « អនុប្រធាន »
- លោក សែត សាម៉ន « អនុប្រធាន »

ដ, នាយកដ្ឋាន ថែទាំសុខភាពជនបទ :

- លោក ដា សំណាង « ប្រធាន »
- លោក ឌិត ស្រេង « អនុប្រធាន »

ឋ, នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ :

- លោក ម៉ៅ សាអ៊ាយ « ប្រធាន »
- លោក ទី យុត្តា « អនុប្រធាន »
- លោក ចាន់ ដារ៉ុង « អនុប្រធាន »

ឌ, ជម្លមណ្ឌលស្រាវជ្រាវ និង តំកល់ឯកសារ :

- លោក ញូង ប៊ូលីណា Supervisor

ឍ, ទីប្រឹក្សា :

- លោក លី សៀងគ្រី
- លោក ជាង គីមអៀង
- លោកស្រី ឈាន់ ស៊ី ដោយជំNancy Boyd

ប្រការ ២ : ប្រកាសនេះ នឹងត្រូវបានបំពេញបន្ថែមតាមគោលការណ៍តែងតាំង ជាធរមានរបស់រដ្ឋ ។

ប្រការ ៣ : សេចក្ដីសំរេចណាដែលផ្ទុយពីប្រកាសនេះ ចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : សេចក្ដីប្រកាសនេះ ចាត់ចូលជាធរមានប្រាកដចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ ៥ : ខុទ្ទកាល័យ អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន ក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទនិងសាមីជន ត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាព ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចេង ហុង ស៊ុនហួត

* * *

៨-ទីស្ដីការក្រសួងធម្មការ និងសាសនា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្ដីប្រកាសលេខ ១៧១/៩៥កធស.ប្រក

ស្ដីពីការផ្ទេរមន្ត្រីរាជការក្នុងក្របខ័ណ្ឌ

ក្រសួងធម្មការ និង សាសនា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីការបង្កើតទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ដែលប្រកាសអោយប្រើតាមប្រកាសលេខ ១៧ ក្រ.ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២

- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ. ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងធម្មការ និងសាសនា
- បានឃើញពាក្យសុំផ្លាស់របស់លោក ហ៊ូ ឆៃអឿន ចុះថ្ងៃទី ០២ សីហា ១៩៩៥

សំរេច

ប្រការ ១ : លោក ហ៊ូ ឆៃអឿន បុគ្គលិកអគ្គាធិការដ្ឋានពុទ្ធិកសិក្សា ត្រូវផ្ទេរអោយទៅធ្វើការនៅមន្ទីរធម្មការ និង សាសនាខេត្តពោធិសាត់ ។

ប្រការ ២ : បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក ហ៊ូ ឆៃអឿន ត្រូវផ្ទេរជូនមន្ទីរធម្មការ និង សាសនាខេត្តពោធិសាត់ ។

ប្រការ ៣ : មន្ទីរធម្មការ និង សាសនាខេត្តពោធិសាត់ និង លោក ហ៊ូ ឆៃអឿន ត្រូវអនុវត្តតាមប្រកាសនេះរៀងៗខ្លួន ។

ប្រការ ៤ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ហឿន_វណ្ណរ័ត្ន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ១៧២/៩៥កធស.

ស្តីពីការអនុញ្ញាតច្បាប់អោយសាងសង់

វិហារឥស្លាម ខេត្តកំពង់ចាម

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងទី ២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរាជរដ្ឋាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញពាក្យស្នើសុំ របស់គណៈកម្មការ ហាកឹមសាសនាឥស្លាម ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយសាងសង់ វិ. ហ្គាមមួយ នៅភូមិមេមត់ថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តកំពង់ចាម ។

ប្រការ ២ : គណៈកម្មការ ហាកឹម ភូមិមេមត់ថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តកំពង់ចាម ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវលិទ្ធិសាសនាដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : គណៈកម្មការហាកឹមភូមិមេមត់ថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តកំពង់ចាម ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះអោ[illegible]មានប្រសិ[illegible]ភាព

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ហៀង ចន្ថារិទ្ធ

* * *

៩ -ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១០៥ បទ.ប្រក.

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតលេខ ៥១៩ បទ.ប ចុះថ្ងៃទី ២៩_០៧ _៩៥ របស់នាយកដ្ឋានប្រៃសណីយ៍
- បានឃើញកំណត់ហេតុ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩៥ របស់ថ្នាក់ដឹកនាំក្រសួង
- ពិនិត្យសមត្ថភាពមន្ត្រីរាជការ
- បានឃើញការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : តែងតាំងបណ្តោះអាសន្នមន្ត្រីរាជការ ចំនួន ០២ រូប នៅនាយកដ្ឋានប្រៃសណីយ៍ អោយទទួលតួនាទីភារកិច្ច ដូចតទៅ ÷

១_លោក **ឡាក់ តារ៉ាវុធ** ជាប្រធានការិយាល័យទូទាត់អន្តរជាតិ

២_លោក **សេង សែនសុគន្ធ** ជាប្រធានការិយាល័យបញ្ញើសារក្នុងនិងក្រៅប្រទេស

ប្រការ ២ : មន្ត្រីរាជការដូចចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមតួនាទីភារកិច្ច និង នៅក្នុងសមត្ថកិច្ចរបស់ខ្លួន ដែលមានចែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ហើយដែលបានផ្ញើជូនរាជរដ្ឋាភិបាលតាមលិខិតលេខ ០៧៧ បទ. ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៣ ។

ប្រការ ៣ : ខុទ្ទកាល័យ , អធិការដ្ឋាន , នាយកដ្ឋានប្រៃសណីយ៍ និងសាមីខ្លួន ០២រូបខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សូ យុន

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១០៦ បន.ប្រក.

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី ០៥_៣_៨៧ ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញប្រកាសលេខ ០៩៤ បទ.ក្រប្រប្រ. ចុះថ្ងៃទី ០៦ ធ្នូ ១៩៩៣ ។
- បានឃើញពាក្យស្នើសុំឈប់ប្រើប្រាស់វិទ្យុប្រភេទ HF និង VHF ចុះថ្ងៃទី ១៤/០៨/៩៥

សម្រេច

ប្រការ ១ : អនុញ្ញាតអោយលោក ម៉ា ឈឿន ប្រធានក្រុមហ៊ុនបុប្ផាអង្គរទេសចរណ៍ផ្អាកឈប់ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF និង VHF ចំនួន ០៤ គ្រឿង ។

ប្រការ ២ : ប្រកាសលេខ ០៩៤បទក្រប្រប្រ ចុះថ្ងៃទី ០៦/១២/៩៣ ទុកជានិរាករណ៍ ។

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និង លោកប្រធានក្រុមហ៊ុនបុប្ផាអង្គរទេសចរណ៍ ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សុ_ឃុន

* * *

១០ -ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១ ប្រ.ខ.ក

ស្តីពីការចាត់តាំងគណៈកម្មការប្រឡងបញ្ចប់

ការសិក្សា ជំនាញស្ថិតិសេដ្ឋកិច្ចជំនាន់ VI

រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ ០២ អរ.ចតប្រ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨២ ស្តីពី បទបញ្ជា ប្រឡងបញ្ចប់ការសិក្សា «អនុវត្តក្នុងបណ្តាឧត្តមសិក្សា » និងមធ្យមសិក្សាឯកទេសរបស់ ក្រសួងអប់រំយុវជន និងកីឡា
- បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១០២ សសរ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៨៦ ស្តីពីការបង្កើតសាលាមធ្យមសិក្សាផែនការ
- តាមសំណូមពរការងារចាំបាច់របស់សាលាមធ្យមសិក្សាផែនការ

សំរេច

ប្រការ ១ : ចាត់តាំងគណៈកម្មការប្រឡងបញ្ចប់ការសិក្សារបស់និស្សិតជំនាន់ VI ផ្នែកស្ថិតិសេដ្ឋកិច្ចដែលមានសមាសភាពដូចខាងក្រោម ÷

១–ឯកឧត្តម **សាន វណ្ណៈ** អនុរដ្ឋលេខាធិការក្រសួងផែនការ ប្រធាន

២–លោក	**ឆ៉ាន លាវ**	ប្រធានមន្ទីរក្រសួងផែនការ	អនុប្រធាន
៣–លោក	**ហ៊ូ តាំងអេង**	ប្រធានវិជ្ជាស្ថានជាតិស្ថិតិ	អនុប្រធាន
៤–លោក	**សាន សុខ**	នាយកសាលា	សមាជិកអចិន្ត្រៃយ៍
៥–លោក	**ស៊ុំ សន្តិសិន**	ប្រធាននាយកដ្ឋានផែនការទូទៅ	សមាជិក
៦–លោក	តំណាងក្រសួងអប់រំយុវជន និងកីឡា		សមាជិក
៧–លោក	**ឆ៉ាល់ មួន**	នាយករងសាលា លេខាធិការសម័យប្រឡង	

ប្រការ ២ : គណៈកម្មការប្រឡងបញ្ចប់ការសិក្សានេះ មានភារកិច្ចចាត់តាំងត្រួតពិនិត្យដំណើរការប្រឡងអោយបានជោគជ័យ និង ជានាប្រសិទ្ធភាព នៃការប្រឡង ។

ប្រការ ៣ : គណៈកម្មការប្រឡងនេះ ត្រូវដំណើរការចាប់ពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ តទៅរហូតដល់ថ្ងៃបញ្ចប់ ។

ប្រការ ៤ : គណៈកម្មការប្រឡងនេះ មានសិទ្ធិប្រើប្រាស់ត្រា ក្រសួងផែនការ ។

ប្រការ ៥ : ឯកឧត្តម អស់លោក ដែលមានរាយនាមក្នុងប្រការ ១ មានភារកិច្ច អនុវត្តសេចក្តីសំរេច នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ជា ចាន់តូ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០២ ប្រ.ផក

ស្តីពីការចាត់តាំងអនុគណៈកម្មការក្រុមពិនិត្យអនុរក្សក្រុម អនុរក្ស ក្រុមទទួលវិញ្ញាសារ ក្រុមអង្គុលីលេខ និងក្រុមសន្តិសុខ ជំនួយអោយគណៈកម្មការប្រឡងបញ្ចប់ការសិក្សារបស់និស្សិតជំនាន់ VI ផ្នែកស្ថិតិសេដ្ឋកិច្ចនៅសាលាមធ្យមសិក្សាផែនការ

រដ្ឋមន្ត្រី ក្រសួងផែនការ

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញប្រកាសលេខ ០១ ប្រ.ផក ចុះថ្ងៃទី ២១ ខែ ៨ ឆ្នាំ ១៩៩៥ ស្តីពីការបាតតាំងគណៈកម្មការប្រឡងបញ្ចប់ការសិក្សាជំនាញស្ថិតិសេដ្ឋកិច្ចជំនាន់ទី VI

– តាមសំណូមពរចាំបាច់របស់សាលាមធ្យមសិក្សាផែនការ

សម្រេច

ប្រការ ១ : បាត់តាំងអនុគណៈកម្មការពេញវិញ្ញាសារ ដើម្បីជំនួយការអោយគណៈកម្មការប្រឡងបញ្ចប់ការសិក្សារបស់និស្សិតជំនាញទី VI ផ្នែកស្ថិតិសេដ្ឋកិច្ចដែលមានសមាសភាពដូចខាងក្រោម ÷

ក–អនុគណៈកម្មការ :

១–ឯកឧត្តម	**សាន វិវណ្ណៈ**	ប្រធាន
២–លោក	**ប៉ាន ឈាវ**	អនុប្រធាន
៣–លោក	**ហ៊ុ ត៉ាងអេង**	អនុប្រធាន
៤–លោក	**សាន សម**	សមាជិកអចិន្ត្រៃយ៍
៥–លោក	**ស៊ុំ សន្តិសិន**	សមាជិក
៦–លោក	**ប៉ាល់ មួន**	សមាជិក
៧–លោក	តំណាងក្រសួងអប់រំយុវជន និង កីឡា	

ខ–ក្រុមពិនិត្យអនុរក្ស :

១–លោក	**ប៉ាន ឈាវ**	ប្រធាន
២–លោក	**ហ៊ុ ត៉ាងអេង**	អនុប្រធាន
៣–លោក	**សាន សម**	សមាជិក
៤–លោក	**ស៊ុំ សន្តិសិន**	សមាជិក
៥–លោក	**ប៉ាល់ មួន**	សមាជិក

៥–លោកតំណាងក្រសួងអប់រំយុវជន និង កីឡា សមាជិក

គ–ក្រុមអនុរក្ស :

១–លោក	ពាង សាធី	ប្រធាន	១ ថ្នាក់
២–លោក	ឡាយ សារិទ្ធ	អនុប្រធាន	១ ថ្នាក់
៣–លោក	ហ៊ុន សុផល	សមាជិក	១ ថ្នាក់
៤–លោក	ចេង រិទ្ធិតារ៉ា	សមាជិក	១ ថ្នាក់
៥–លោក	ឈឹម ឧត្តា	សមាជិក	១ ថ្នាក់
៦–លោក	ណៃ ចាន់ធី	សមាជិក	១ ថ្នាក់
១–លោក	អ៊ុន គីមជរ	ប្រធាន	១ ថ្នាក់
២–លោក	អៀង ឫទ្ធី	អនុប្រធាន	១ ថ្នាក់
៣–លោក	កែម ទិបុល	សមាជិក	១ ថ្នាក់
៤–លោក	ហេង សារា	សមាជិក	១ ថ្នាក់
៦–លោក	ញ៉ាញ់ ជីញ៉ក់	សមាជិក	១ ថ្នាក់
១–លោក	គួ ផានី	ប្រធាន	១ ថ្នាក់
២–លោក	ចាន់ សារុន	អនុប្រធាន	១ ថ្នាក់
៣–លោក	ចាន់ រិទ្ធី	សមាជិក	១ ថ្នាក់
៤–លោក	រស់ ស៊ីនួន	សមាជិក	១ ថ្នាក់
៥–លោក	ហ៊ូ តារ៉ា	សមាជិក	១ ថ្នាក់

ឃ–ក្រុមទទួលវិញ្ញាសារ :

១–លោក	អេង ជិនលី	ប្រធាន
២–លោកស្រី	ស៊ិន ធារី	សមាជិក
៣–លោកស្រី	ឡិ ឈឺន	សមាជិក

ង–ក្រុមអង្គុលីលេខ និង ភេសជ្ជៈ :

១–លោកស្រី ឃ្លោក សាម៉េត

២–លោកស្រី ហង់ ផល្លី

៣-លោកស្រី អៀង គៅ

៤-លោក ម៉ឺន សារ៉ាន់

ច-ក្រុមសន្តិសុខ :

១-លោកស្រី ឈុម សុផល ប្រធាន

២-លោក ផេន ញ៉ឹង សមាជិក

៣-លោក ស្វាយ ផារត សមាជិក

៤-លោក យិន សឿន សមាជិក

ប្រការ ២ : អនុគណៈកម្មការពិនិត្យអនុរក្ស ក្រុមអនុរក្ស និងក្រុមទទួលវិញ្ញាសារស្ថិតនៅ ក្រោមការណែនាំរបស់គណៈកម្មការប្រឡងបញ្ចប់ការសិក្សា និងទទួលខុសត្រូវក្នុងការងារដោះស្រាយរាល់បញ្ហាកើតមានឡើងនៅពេលប្រឡង ។

ប្រការ ៣ : អនុគណៈកម្មការ និងក្រុមពិនិត្យអនុរក្ស ត្រូវផ្តើមធ្វើការងាររបស់ខ្លួនតាមកម្មវិធីប្រឡងនៅសាលាមធ្យមសិក្សាផែនការ ។

ប្រការ ៤ : ឯកឧត្តម អស់លោក លោកស្រី ដែលមានរាយនាមនៅក្នុងប្រការ ១ ត្រូវទទួលភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

សាន វណ្ណៈ

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១៤១៤ រៀល